

## ការណែនាំបំភ្លឺអំពី

# ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម

បោះពុម្ពលើកទី ៤

# មាតិកា


សំណួរទី ១ : ហេតុអ្វីបានជាប្រើរយៈពេលយូរម្ល៉េះទើបចាប់ផ្តើមជំនុំជម្រះក្តីអ្នកដែលត្រូវបានចោទប្រកាន់ថា
បានទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម ? ........ ៨

សំណួរទី ២ : ហេតុអ្វីបានជាយើងទើបកាត់ក្តីនៅពេលនេះ ? តើការកាត់ក្តីមេដឹកនាំខ្មែរក្រហមនឹងផ្តល់
ផលប្រយោជន៍អ្វីខ្លះដល់ប្រជាជនកម្ពុជា ? ........ ៨

សំណួរទី ៣ : តើនរណាខ្លះនឹងត្រូវនាំយកមកកាត់ក្តី ? ........ ៩

សំណួរទី ៤ : តើជនសង្ស័យនឹងទទួលទោសយ៉ាងដូចម្តេចប្រសិនបើតុលាការរកឃើញថាគាត់មានទោស ? ........ ១១

សំណួរទី ៥ : តើមានការលើកលែងទោសឬការអនុគ្រោះទោសដែរឬទេ ? ........ ១១

សំណួរទី ៦ : តើធ្លាប់មានមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមណាត្រូវបានកាត់ក្តីពីមុនមកឬទេ ? ........ ១២

សំណួរទី ៧ : តើបណ្តាប្រទេសដែលធ្លាប់បានគាំទ្រឬក៏ជាប់ពាក់ព័ន្ធជាមួយកម្ពុជាប្រជាធិបតេយ្យ ឬក៏បណ្តាប្រទេស
ដែលប្រហែលជាបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមនៅកម្ពុជាមុនឆ្នាំ១៩៧៥ នឹងត្រូវកាត់ទោសដែរឬទេ ? ........ ១២

សំណួរទី ៨ : តើនឹងមានការកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទថាបានប្រព្រឹត្តដោយមេដឹកនាំ
ជាន់ខ្ពស់ខ្មែរក្រហម ឬអ្នកដទៃទៀតក្រោយឆ្នាំ១៩៧៩ ដែរឬទេ ? ........ ១២

សំណួរទី ៩ : តើតុលាការចាប់ផ្តើមជំនុំជម្រះក្តីនៅពេលណា ? ........ ១៣

សំណួរទី ១០ : តើការជំនុំជម្រះក្តីនឹងប្រើរយៈពេលប៉ុន្មានឆ្នាំ ? ........ ១៣

សំណួរទី ១១ : តើការជំនុំជម្រះក្តីនេះកំពុងប្រព្រឹត្តទៅនៅកន្លែងណា ? ........ ១៤

សំណួរទី ១២ : តើអង្គជំនុំជម្រះវិសាមញ្ញធ្វើការរបៀបដូចម្តេច ? ........ ១៤

សំណួរទី ១៣ : តើនរណាខ្លះអាចចូលទៅស្តាប់ការកាត់ក្តីបាន ? ........ ១៥

សំណួរទី ១៤ : ប្រសិនបើយើងមិនអាចចូលមើលការកាត់ក្តីនេះបាន តើធ្វើដូចម្តេចយើងអាចដឹងបានពីអ្វីដែលកំពុងកើតឡើងនៅក្នុងតុលាការ ? ........ ១៥

សំណួរទី ១៥ : តើចៅក្រមត្រូវតែងតាំងឡើងយ៉ាងដូចម្តេច ? ........ ១៦

សំណួរទី ១៦ : តើចៅក្រមនឹងឈានដល់ការចេញសេចក្តីសម្រេចយ៉ាងដូចម្តេច ? ........ ១៦

សំណួរទី ១៧ : តើនរណាជាអ្នកសម្រេចថាជនណាខ្លះនឹងត្រូវកាត់សេចក្តី ? តើនរណាជាអ្នកសម្រេចថាពួកគេនឹងត្រូវចោទប្រកាន់ពីបទល្មើសអ្វី ? ........ ១៧

សំណួរទី ១៨ : តើមានអ្វីកើតឡើង ប្រសិនបើសហព្រះរាជអាជ្ញាឬសហចៅក្រមស៊ើបអង្កេតមិនយល់ស្របគ្នាថាតើត្រូវបញ្ជូនរឿងក្តីទៅកាត់សេចក្តីឬមិនបញ្ជូន ? ........ ១៧


រូបថតក្របមុខៈ ការអុជធូបឧទ្ទិសកុសលជូនព្រលឹងជនរងគ្រោះនៃរបបខ្មែរក្រហម នៅបូជនីយដ្ឋានជើងឯក     រូបថតដោយៈ ជ សុគន្ធា

*រក្សាសិទ្ធគ្រប់យ៉ាង © ឆ្នាំ២០១០*

សំណួរទី ១៩ : តើចៅក្រមនៅសាលាដំបូងធ្វើការងារអ្វីខ្លះ ? ........ ១៨
សំណួរទី ២០ : តើភស្តុតាងអ្វីខ្លះនឹងត្រូវប្រើប្រាស់នៅពេលកាត់សេចក្តី ? ........ ១៩
សំណួរទី ២១ : តើបទឧក្រិដ្ឋអ្វីនឹងត្រូវលើកយកមកកាត់ក្តី ? តើការកាត់ក្តីប្រើច្បាប់កម្ពុជាឬក៏ច្បាប់ អន្តរជាតិ ? ........ ១៩
សំណួរទី ២២ : តើចុងចោទមានសិទ្ធិអ្វីខ្លះ ? ........ ២០
សំណួរទី ២៣ : តើអ្នកណាខ្លះនឹងត្រូវកោះអញ្ជើញឲ្យធ្វើជាសាក្សី ? ........ ២១
សំណួរទី ២៤ : តើខ្ញុំត្រូវផ្តល់ព័ត៌មានទៅឲ្យតុលាការដែរឬទេ ? ........ ២២
សំណួរទី ២៥ : តើខ្ញុំត្រូវធ្វើយ៉ាងដូចម្តេចប្រសិនបើខ្ញុំចង់ផ្តល់ព័ត៌មានអំពីនរណាម្នាក់ដែលខ្ញុំជឿជាក់ថា បានប្រព្រឹត្តបទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរក្នុងអំឡុងរបបខ្មែរក្រហម ? ........ ២២
សំណួរទី ២៦ : តើការគាំទ្រអ្វីខ្លះនឹងត្រូវផ្តល់ទៅឲ្យសាក្សី និងជនរងគ្រោះដែលផ្តល់សក្ខីកម្ម និងសម្រាប់មនុស្សទូទាំងប្រទេស ដែលអាចនឹងមានការឈឺចាប់ក្នុងចិត្តនៅពេលស្តាប់ឮសក្ខីកម្មដែលបានបង្ហាញនៅក្នុងតុលាការ ? ........ ២២
សំណួរទី ២៧ : តើជនរងគ្រោះអាចចូលរួមក្នុងសវនាការតាមវិធីណា ? ........ ២៣
សំណួរទី ២៨ : តើជនរងគ្រោះមានសិទ្ធិទទួលបានសំណងដែរឬទេ ? ........ ២៤
សំណួរទី ២៩ : ហេតុអ្វីបានជាអង្គការសហប្រជាជាតិចូលរួមក្នុងដំណើរការនេះ ? ........ ២៤
សំណួរទី ៣០ : ហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមមិនត្រូវបានយកទៅកាត់សេចក្តីនៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ( ICC ) នៅទីក្រុងឡាអេ ឬក្នុងតុលាការយុត្តិធម៌អន្តរជាតិ ( ICJ ) ? ........ ២៥
សំណួរទី ៣១ : តើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាតុលាការកម្ពុជាឬជាតុលាការអន្តរជាតិ ? ........ ២៥
សំណួរទី ៣២ : តើមានតុលាការផ្សេងទៀត នៅក្នុងពិភពលោកដែលលក្ខណៈដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ ? ........ ២៥
សំណួរទី ៣៣ : ហេតុអ្វីបានជាតុលាការប្រភេទនេះត្រូវបានយកមកប្រើសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ? ........ ២៦
សំណួរទី ៣៤ : តើដំណើរការកាត់ក្តីនេះត្រូវចំណាយថវិកាប៉ុន្មាន ? ........ ២៦
សំណួរទី ៣៥ : តើតុលាការនេះទទួលថវិកាមកពីប្រភពណាខ្លះ ? ........ ២៦
សំណួរទី ៣៦ : តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមអំពីរឿងខ្មែរក្រហមនិងដំណើរការកាត់ក្តីទាំងនេះដោយវិធីណា ? ........ ២៧
សំណួរទី ៣៧ : តើអង្គការក្រៅរដ្ឋាភិបាលមានតួនាទីអ្វីខ្លះ ? ........ ២៨
សំណួរទី ៣៨ : តើខ្ញុំអាចទទួលសេវាគាំទ្រសម្រាប់រូបខ្ញុំនៅទីណាបាន ? ........ ២៨

# អារម្ភកថា



ដោយសម្ដេចអគ្គមហា
សេនាបតីតេជោ **ហ៊ុន សែន**
*នាយករដ្ឋមន្ត្រី*
*នៃព្រះរាជាណាចក្រកម្ពុជា*

## បងប្អូនរួមជាតិជាទីស្នេហា!

គ្មានប្រជាជនយើងណាម្នាក់បានគេចផុតពីការបំផ្លិចបំផ្លាញដែលប្រព្រឹត្តមកលើមាតុភូមិជាទីស្នេហារបស់យើង ក្នុងអំឡុងពេល ៣ ឆ្នាំ ៨ខែ និង២០ថ្ងៃ ដែលពួកខ្មែរក្រហម ប៉ុល ពត កាន់អំណាចនៅក្រោមរបបមួយដែលគេស្គាល់ឈ្មោះថា កម្ពុជាប្រជាធិបតេយ្យ នោះទេ។

ក្នុងរយៈពេលនោះ ប្រជាជនយើងជាង ៣ លាននាក់ បានបាត់បង់ជីវិត។ អ្នកទាំងនោះ គឺជាឪពុក ម្ដាយ កូន សាច់ញាតិ មិត្តរួមការងារ( សហសេវិក ) និងមិត្តភ័ក្តិរបស់យើង។ យើងទាំងអស់គ្នាដែលនៅសល់ពីស្លាប់បានរស់នៅអស់រយៈពេលជាង ២៥ឆ្នាំ ដោយក្ដីឈឺចាប់ខ្លោចផ្សា សោកសង្រេងដល់អ្នកដែលបានបាត់បង់ជីវិតទៅហើយ និងសុបិនអាក្រក់នៃអនុស្សាវរីយ៍ដ៏ជូរចត់របស់យើងតាមលងឥតស្រាកស្រាន្ត។

សូម្បីតែបងប្អូនរួមជាតិដែលកើតក្រោយឆ្នាំ១៩៧៩ ដែលមិនបានជួបប្រទះផ្ទាល់នូវឧក្រិដ្ឋកម្មទាំងនោះក៏ទទួលរងនូវបន្ទុកដ៏ធ្ងន់ធ្ងរដែរ។ បងប្អូនឃើញពុកម៉ែ និងសាច់ញាតិប្រុសស្រី របស់បងប្អូនកំពុងឈឺចាប់ខ្លោចផ្សានៅឡើយ។ បងប្អូនក៏រួមចំណែកផងដែរ នូវរាល់ការលំបាកក្នុងការកសាងសង្គមជាតិយើងឡើងវិញពីបាតដៃទទេ ឬឆ្នាំសូន្យដោយមិនបានទទួលអត្ថប្រយោជន៍នៃគតិបណ្ឌិត និងបទពិសោធន៍ពីញាតិមិត្តដែលបានស្លាប់ទៅហើយនោះទេ។

យើងបាន និងកំពុងតស៊ូយ៉ាងខ្លាំងក្លា ដើម្បីស្ដារប្រទេសជាតិឡើងវិញ ហើយយើងទាំងអស់គ្នាដឹងថាកម្ពុជា សព្វថ្ងៃនេះមានលក្ខណៈអន់ថយឆ្ងាយជាងបណ្ដាប្រទេសជិតខាងក្នុងវិស័យសុខាភិបាល អប់រំ និងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច។

ឥឡូវនេះ ពេលវេលាបានមកដល់ហើយ សម្រាប់នាំយកអ្នកទាំងឡាយណាដែលទទួលខុសត្រូវក្នុងការរៀបចំផែនការ និងបញ្ជាឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មព្រៃផ្សៃឲ្យមកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត។ ដោយអនុលោមទៅតាមការចរចាជាមួយអង្គការសហប្រជាជាតិ អស់រយៈពេលជាច្រើនឆ្នាំ តុលាការថ្មីមួយរបស់កម្ពុជាត្រូវបានបង្កើតឡើងដោយមានបញ្ចូលមន្ត្រីបម្រើការងារ និងចៅក្រមអន្តរជាតិ។ ឈ្មោះជាផ្លូវការរបស់តុលាការនេះ គឺអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ

កម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ តុលាការនេះគឺជាតុលាការដំបូងនៅក្នុងពិភពលោកដែលជំនុំជម្រះក្តីបែបនេះ។

ឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលរបបខ្មែរក្រហម មិនត្រឹមតែបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនកម្ពុជាប៉ុណ្ណោះទេ ថែមទាំងប្រឆាំងនឹងមនុស្សជាតិទាំងមូលផងដែរ។ ដូចនេះ វាសមស្របណាស់ដែលពលរដ្ឋកម្ពុជាត្រូវសហការជាមួយសហគមន៍អន្តរជាតិដើម្បីជំនុំជម្រះទោសជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ហើយការធ្វើដូច្នេះនឹងជួយបង្កើតនូវវប្បធម៌មួយដែលទប់ស្កាត់មិនឲ្យមានការកើតឡើងសាជាថ្មីនៃឧក្រិដ្ឋកម្មបែបនេះនៅគ្រប់ទិសទីនៃពិភពលោក។ យើងសង្ឃឹមថា តុលាការថ្មីរបស់យើងនឹងក្លាយទៅជាតុលាការគំរូដ៏ជោគជ័យ ដែលមិនមែនសម្រាប់តែកម្ពុជាប៉ុណ្ណោះទេ គឺថែមទាំងផ្តល់វិភាគទានដ៏ទូលំទូលាយដល់ប្រព័ន្ធយុត្តិធម៌ពិភពលោកផងដែរ។

ខ្ញុំមានជំនឿថា បងប្អូនរួមជាតិនឹងចូលរួមជាមួយខ្ញុំក្នុងក្តីសង្ឃឹមថា ការជំនុំជម្រះក្តីនេះនឹងប្រព្រឹត្តទៅនៅក្នុងសភាពថ្លៃថ្នូរ និងសន្តិភាព។ ពេលដែលចៅក្រមប្រកាសសាលក្រម យើងសង្ឃឹមថា ប្រជាជនកម្ពុជានិងអ្នកទាំងឡាយណាដែលគាំទ្រយើងនឹងឃើញថា នៅទីបញ្ចប់ យើងនឹងនាំមកនូវយុត្តិធម៌ក្នុងនាមនៃជនរងគ្រោះ។



នាយករដ្ឋមន្ត្រី

# សេចក្តីផ្តើម



ដោយឯកឧត្តម **សុខ អាន**
*ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាសម្រាប់កិច្ចសហប្រតិបត្តិការជាមួយអ្នកជំនាញការអន្តរជាតិផ្នែកច្បាប់ និងការរៀបចំដំណើរការកាត់ក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម*

របបខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយត្រូវទម្លាក់ចុះពីអំណាចនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ប្រជាជនជាង ៣ លាននាក់ បានបាត់បង់ជីវិត។ សង្គ្រាមស៊ីវិលបានបន្តក្រោយពីការដួលរលំនៃរបបខ្មែរក្រហម។ នៅទីបំផុត សង្គ្រាមស៊ីវិលត្រូវបានបញ្ចប់នៅឆ្នាំ១៩៩៨ នៅពេលដែលរចនាសម្ព័ន្ធនយោបាយនិងយោធារបស់ខ្មែរក្រហមត្រូវកម្ទេចចោល។

នៅឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានសំណូមពរឲ្យអង្គការសហប្រជាជាតិជួយឧបត្ថម្ភសាលាក្តី ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។

នៅឆ្នាំ២០០១ រដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់មួយ ដើម្បីបង្កើតតុលាការកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅប្រទេសកម្ពុជាក្នុងអំឡុងពេលរបបខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩។ តុលាការនេះមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬ អ.វ.ត.ក)។

រាជរដ្ឋាភិបាលកម្ពុជាបានទទូចសុំថា ដើម្បីជាផលប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់ តុលាការជម្រះក្តីត្រូវប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់មន្ត្រី និងចៅក្រមកម្ពុជាគួបផ្សំជាមួយមន្ត្រីនិងចៅក្រមអន្តរជាតិ។ កម្ពុជាបានអញ្ជើញសហគមន៍អន្តរជាតិឲ្យចូលរួមសហការក្នុងការកាត់សេចក្តីនេះ ដើម្បីធានាឲ្យមានយុត្តិធម៌ជាលក្ខណៈស្តង់ដារអន្តរជាតិ ព្រោះកម្ពុជាយល់ឃើញថា ខ្លួននៅទន់ខ្សោយផ្នែកតុលាការ ហើយឧក្រិដ្ឋកម្មនេះមានចរិតលក្ខណៈជាឧក្រិដ្ឋកម្មអន្តរជាតិ។ ចុងបញ្ចប់កិច្ចព្រមព្រៀងមួយជាមួយអង្គការសហប្រជាជាតិត្រូវបានចុះហត្ថលេខានៅខែមិថុនា ឆ្នាំ២០០៣ ដែលចែងអំពីថាតើសហគមន៍អន្តរជាតិនឹងជួយឧបត្ថម្ភនិងសហការរបៀបដូចម្តេចនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ។

តុលាការថ្មី និងពិសេសនេះ ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ប៉ុន្តែតុលាការនេះគឺជាតុលាការឯករាជ្យម្ចាស់ការ និងមិនចំណុះឲ្យរាជរដ្ឋាភិបាលឬអង្គការសហប្រជាជាតិឡើយ។ តុលាការនេះគឺជាតុលាការកម្ពុជាដែលមានការចូលរួមពីសហគមន៍អន្តរជាតិ ដែលនឹងអនុវត្តទៅតាមស្តង់ដារអន្តរជាតិ។ តុលាការនេះនឹងក្លាយជាគំរូថ្មីមួយសម្រាប់ដំណើរការកាត់ក្តីនៅកម្ពុជា។

កូនសៀវភៅនេះនឹងណែនាំបំភ្លឺលោកអ្នកអំពីអង្គជំនុំជម្រះវិសាមញ្ញ ហើយឆ្លើយតបទៅនឹងសំណួរមួយចំនួនដែលប្រជាជនឧស្សាហ៍សាកសួរអំពីការជំនុំជម្រះក្តីនេះ។ នៅពេលនេះ អង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងរួចហើយ ផ្នែកកិច្ចការសាធារណៈនៃសាលាក្តីអាចផ្តល់ព័ត៌មានបន្ថែមដល់សាធារណជននិងប្រព័ន្ធសារព័ត៌មាននានាបាន។

ឧបនាយករដ្ឋមន្ត្រី

# សារលិខិត



របស់លោក **បាន គីមូន**

*អគ្គលេខាធិការអង្គការសហប្រជាជាតិ*

*ខែ ធ្នូ ឆ្នាំ ២០១០*

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើងដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាដែលបានឆ្លងកាត់ឧក្រិដ្ឋកម្មគួរឲ្យតក់ស្លុត ដែលបានកើតឡើងនៅកម្ពុជាក្នុងទសវត្សរ៍ឆ្នាំ១៩៧០។ ចាប់តាំងពីពេលចាប់ផ្តើមដំណើរការនៅខែមករា ឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញបានវិវឌ្ឍទៅមុខគួរឲ្យកត់សម្គាល់។ សាលក្រមក្នុងសំណុំរឿង ០០១ លើករណីប្រធានមន្ទីរ ស-២១ សបញ្ជាក់អំពីសមត្ថភាពរបស់ អ.វ.ត.ក ក្នុងការជំនុំជម្រះលើសំណុំរឿងស្មុគស្មាញស្របតាមបទដ្ឋានអន្តរជាតិ ហើយដីកាចោទប្រកាន់និងបញ្ជូនរឿងទៅជំនុំជម្រះលើអតីតមេដឹកនាំ ៤ រូប នៃរបបខ្មែរក្រហមក្នុងសំណុំរឿង ០០២ បញ្ជាក់ជាថ្មីម្តងទៀតថា គ្មាននរណាអាចគេចផុតពីសំណាញ់ច្បាប់បានឡើយ។

ក្នុងនាមជាដៃគូការងារជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិគាំទ្រ និងគោរពទាំងស្រុងនូវនីតិវិធីឯករាជ្យរបស់ អ.វ.ត.ក ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ចប់និទណ្ឌភាពនៃអំពើឃោរឃៅក្នុងអំឡុងរបបខ្មែរក្រហម អ.វ.ត.ក កំពុងជួយពង្រឹងនីតិរដ្ឋ ក៏ដូចជាសមត្ថភាពចៅក្រមកម្ពុជា ហើយក្នុងពេលដំណាលគ្នានេះ ជំរុញឲ្យមានការយល់ដឹងកាន់តែប្រសើរឡើងអំពីវិស័យយុត្តិធម៌នៃឧក្រិដ្ឋកម្មអន្តរជាតិ។ ចំណុចសំខាន់បំផុតគឺខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងធ្វើឲ្យប្រជាជនកម្ពុជាដែលកំពុងទន្ទឹងរង់ចាំយុត្តិធម៌អស់ពេលជាយូរ មានលទ្ធភាពបិទទំព័រដ៏ខ្មៅងងឹតនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួនបានជាស្ថាពរ។

## សំណួរទី ១ ហេតុអ្វីបានជាប្រើរយៈពេលយូរម្ល៉េះ ទើបចាប់ផ្តើមជំនុំជម្រះក្តី អ្នកដែលត្រូវបានចោទប្រកាន់ថាបានទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម ?

ប្រវត្តិសាស្ត្របានបង្ហាញឲ្យឃើញថា ពេលប្រទេសនៅមានសង្គ្រាម ការកាត់សេចក្តីជួបប្រទះការលំបាកខ្លាំង។ សង្គ្រាមស៊ីវិលនៅកម្ពុជាទើបតែបានបញ្ចប់ទៅនៅក្នុងឆ្នាំ១៩៩៨ ប៉ុណ្ណោះ។ ចាប់តាំងពីប្រទេសកម្ពុជាស្នើសុំឲ្យអង្គការសហប្រជាជាតិជួយនៅឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានសហការគ្នាឆ្ពោះទៅរកការអនុវត្តជាបណ្តើរៗនូវទម្រង់ថ្មីមួយនៃសាលាជំនុំជម្រះក្តីចម្រុះជាតិនិងអន្តរជាតិ។ ដូច្នេះ វាត្រូវប្រើរយៈពេលយូរបន្តិចដើម្បីសិក្សានូវបញ្ហាលម្អិតជាច្រើនដើម្បីឲ្យតុលាការគំរូថ្មីមួយនេះអាចដំណើរការទៅបាន។



រូបថត: មជ្ឈមណ្ឌលឯកសារកម្ពុជា

*កងទ័ពខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥*

នៅឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានតែងតាំងក្រុមការងារមួយ ដើម្បីរៀបចំការកាត់ក្តី និងធ្វើការចរចាជាមួយអង្គការសហប្រជាជាតិ។ ការចរចានេះមានរយៈពេលយូរនិងមានភាពស្មុគស្មាញច្រើន ទម្រាំភាគីទាំងពីរឯកភាពគ្នានៅឆ្នាំ២០០៣ លើខ្លឹមសារលម្អិតនៃការចូលរួមរបស់សហគមន៍អន្តរជាតិ។

តុលាការកូនកាត់ថ្មីមួយនេះមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬ អ.វ.ត.ក ហើយបានដំណើរការពេញលេញជាផ្លូវការនៅខែមិថុនា ឆ្នាំ២០០៧។

## សំណួរទី ២ ហេតុអ្វីបានជាយើងទើបធ្វើការកាត់ក្តីនៅពេលនេះ ? តើការកាត់ក្តីខ្មែរក្រហមនេះនឹងផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ប្រជាជនកម្ពុជា ?

អស់រយៈពេលជាង ២៥ ឆ្នាំ កន្លងមកហើយ ដែលប្រជាជនកម្ពុជាបានរង់ចាំយុត្តិធម៌។ ចុងបញ្ចប់ ពេលវេលាបានមកដល់ហើយសម្រាប់ឲ្យមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរដែលខ្លួនបានប្រព្រឹត្តក្នុងសម័យនោះ មកទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្ត។

អង្គជំនុំជម្រះវិសាមញ្ញត្រូវបង្កើតឡើងដើម្បីកាត់សេចក្តីជាសាធារណៈនិងប្រកបដោយយុត្តិធម៌សមស្របទៅនឹងបទដ្ឋានអន្តរជាតិ។ គោលដៅសំខាន់នៃតុលាការនេះគឺផ្តល់យុត្តិធម៌ជូនប្រជាជនកម្ពុជា ទាំងអ្នកដែលបាត់បង់ជីវិតនិងអ្នកដែលនៅរស់។ មានការរំពឹងទុកថា ការកាត់សេចក្តីប្រកបដោយយុត្តិធម៌នេះនឹងជួយធ្វើឲ្យអ្នកដែលនៅរស់ពីការសម្លាប់រង្គាល បានធូរស្បើយពីរបួសអតីតកាល។ ការកាត់ក្តីនេះក៏មានប្រយោជន៍ផងដែរសម្រាប់មនុស្សជំនាន់ក្រោយគឺអប់រំកុលបុត្រកុលធីតាកម្ពុជាឲ្យយល់ដឹងពីទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនៃប្រទេសរបស់យើង។



រូបថត: មជ្ឈមណ្ឌលឯកសារកម្ពុជា

*ព្រះសង្ឃកំពុងមើលរូបថតអ្នកទោសនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង*

តាមរយៈការវិនិច្ឆ័យជនជាប់ចោទជាសាធារណៈនិងប្រកបដោយយុត្តិធម៌ ព្រមទាំងការដាក់ទណ្ឌកម្មជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ការជំនុំជម្រះនេះនឹងជួយពង្រឹងនីតិរដ្ឋរបស់យើង ព្រមទាំងជាគំរូមួយដល់ជនទាំងឡាយណាដែលមិនគោរពច្បាប់នៅកម្ពុជា និងសម្រាប់របបឃោរឃៅនៅទូទាំងពិភពលោក។

ប្រសិនបើឧក្រិដ្ឋជនដឹងថា ពួកគេនឹងទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ពួកគេប្រហែលជាញញើតមិនហ៊ានប្រព្រឹត្តបទឧក្រិដ្ឋទេ។ យើងទាំងអស់គ្នាអាចរួមវិភាគទានក្នុងការស្តារសង្គមជាតិយើងឡើងវិញ ដោយការគាំទ្រនិងការរៀនសូត្រអំពីយុត្តិធម៌។

**សំណួរទី ៣**

## តើអ្នកណាខ្លះនឹងត្រូវនាំយកមកកាត់ក្តី?

ក្នុងស្មារតីចង់បានយុត្តិធម៌ ការពិត និងការផ្សះផ្សាជាតិ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានឯកភាពគ្នាថា អង្គជំនុំជម្រះវិសាមញ្ញនេះគប្បីកម្រិតយុត្តាធិការចំពោះតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ (ឈ្មោះរដ្ឋដែលបង្កើតដោយខ្មែរក្រហម) ដែលត្រូវបានចោទថាបានរៀបចំផែនការ ឬចេញបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនានា និងអ្នកទាំងឡាយណាដែលត្រូវបានចោទថាមានការទទួលខុសត្រូវខ្ពស់បំផុតក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ។ គេរំពឹងថាមានតែជនមួយចំនួនតូចតែប៉ុណ្ណោះដែលស្ថិតក្រោមនិយមន័យនេះ និងដែលត្រូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាំយកមកកាត់សេចក្តី។

ប៉ុន្មានឆ្នាំកន្លងមកនេះ កងទ័ពរបស់ខ្មែរក្រហមរាប់ម៉ឺននាក់បានចុះចូលជាមួយរាជរដ្ឋាភិបាល។ ពួកគាត់គ្មានអ្វីដែលត្រូវភ័យខ្លាចអំពីតុលាការនេះទេ។ គោលនយោបាយផ្សះផ្សាជាតិស្ថិតនៅជាធរមាននៅឡើយ។ សូមចងចាំថា មានតែជនដែលប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរតែប៉ុណ្ណោះ ដែលនឹងត្រូវកាត់ក្តីនៅក្រោមច្បាប់ដែលមានចែងនៅក្នុងសាលាក្តីពិសេសនេះ។

តុលាការវិសាមញ្ញនេះ នឹងមានការទទួលខុសត្រូវក្នុងការសម្រេចចិត្តថា តើខ្មែរក្រហមមួយណាជា "មេដឹកនាំជាន់ខ្ពស់ ហើយអ្នកណាដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុត" ក្នុងឧក្រិដ្ឋកម្មពេលនោះ។ តុលាការនឹងស្វែងរកតែមុខសញ្ញាទាំងនោះ គឺមិនមែនស្វែងរកគ្រប់អតីតសមាជិកខ្មែរក្រហម ឬមនុស្សម្នានៅក្នុងបណ្តាភូមិផ្សេងៗទូទាំងកម្ពុជា ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមកាន់កាប់អំណាចនោះទេ។

- សមាជិកខ្មែរក្រហមដែលមានបណ្ដាស័ក្តិទាបឬមធ្យម ដែលមិនមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងនោះ នឹងមិនត្រូវយកមកកាត់ទោសទេ។ ពួកគាត់ភាគច្រើន ឥឡូវនេះបានចូលរួមនៅក្នុងសង្គមឡើងវិញហើយ។ យើងសង្ឃឹមថា អ្នកទាំងនោះនឹងរស់នៅដោយសុខសាន្ត និងជួយសហការអភិវឌ្ឍប្រទេសជាតិ។
- កូន ឬសមាជិកគ្រួសារផ្សេងៗទៀត ឬអ្នកធ្លាប់រាប់អានមេដឹកនាំខ្មែរក្រហម នឹងមិនទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជំនួសឪពុកម្ដាយ ឬសហគមន៍របស់ខ្លួនទេ។
- អ្នកដែលបានស្លាប់បាត់បង់ជីវិតទៅ នឹងមិនត្រូវបានកាត់ទោសឡើយ។ តុលាការកាត់ក្ដីតែអ្នកដែលនៅរស់ប៉ុណ្ណោះ។


Tom Fawthrop

*កងទ័ពខ្មែរក្រហមបន្ទាប់ពីទម្លាក់អាវុធនិងចុះចូលជាមួយកងកម្លាំងប្រដាប់អាវុធកម្ពុជា*

បច្ចុប្បន្ននេះ តុលាការបានឃុំខ្លួននិងចោទប្រកាន់មនុស្សចំនួន ៥ រូប។

## សំណុំរឿង ០០១

**កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** (អតីតប្រធានមន្ទីរស-២១) ត្រូវបានអង្គជំនុំជម្រះសាលាដំបូងផ្តន្ទាទោសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ គាត់ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ៣៥ ឆ្នាំ ហើយត្រូវបានកាត់បន្ថយមកត្រឹមរយៈពេល ៣០ឆ្នាំ ជាការទូទាត់សំណងទៅនឹងការឃុំខ្លួនគាត់ដោយមិនប្រក្រតីកន្លងមកដោយតុលាការយោធាកម្ពុជា។ ជនជាប់ចោទ សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមទៅកាន់អង្គជំនុំជម្រះតុលាការកំពូល។ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខនឹងត្រូវធ្វើឡើងនៅឆ្នាំ២០១១ ។

## សំណុំរឿង ០០២

**នួន ជា** (អតីតប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យ និងអនុលេខាបក្សកុម្មុយនីស្តកម្ពុជា) ត្រូវបានចោទប្រកាន់ពីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនានៅក្រោមច្បាប់កម្ពុជា។

**អៀង សារី** (អតីតរដ្ឋមន្ត្រីការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ) ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា នៅក្រោមច្បាប់កម្ពុជា។



កាំង ហ្កេកអ៊ាវ ហៅ ឌុច



នួន ជា



អៀង សារី



អៀង ធីរិទ្ធ



ខៀវ សំផន

**អៀង ធីរិទ្ធ** (អតីតរដ្ឋមន្ត្រីសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ) ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា នៅក្រោមច្បាប់កម្ពុជា។

**ខៀវ សំផន** (អតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ) ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា នៅក្រោមច្បាប់កម្ពុជា។

សហព្រះរាជអាជ្ញាអន្តរជាតិក៏បានស្នើសុំសហចៅក្រមស៊ើបអង្កេតឲ្យស៊ើបអង្កេតបទឧក្រិដ្ឋផ្សេងៗទៀតទាក់ទងនឹងជនសង្ស័យចំនួន ៥ នាក់បន្ថែមទៀត។ ការស៊ើបអង្កេតបានចាប់ផ្តើមក្នុងឆ្នាំ២០១០ ហើយរហូតមកដល់ពេលនេះ មិនទាន់មានការចោទប្រកាន់ឬការចាប់ខ្លួនជនសង្ស័យណាម្នាក់បន្ថែមទៀតឡើយ។

សំណួរទី ៤

## តើជនសង្ស័យនឹងទទួលនូវការដាក់ទោសអ្វីខ្លះ ប្រសិនបើតុលាការរកឃើញថាពួកគាត់មានទោស?

ទោសអតិបរមាគឺការដាក់ពន្ធនាគារអស់មួយជីវិត ហើយការដាក់ទោសអប្បរមាគឺការដាក់ពន្ធនាគាររយៈពេល ៥ ឆ្នាំ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឲ្យមានទោសប្រហារជីវិតទេ។ បន្ថែមពីលើនេះ តុលាការអាចបញ្ជាឲ្យធ្វើការរឹបអូសទ្រព្យសម្បត្តិឬថវិកាដែលចុងចោទទទួលបានមិនស្របច្បាប់ ឬដោយការប្រព្រឹត្តិបទឧក្រិដ្ឋណាមួយ។ ទ្រព្យសម្បត្តិដែលបានរឹបអូសនេះនឹងត្រូវប្រគល់ជូនរដ្ឋ។

សំណួរទី ៥

## តើមានការលើកលែងទោសឬការអនុគ្រោះទោសដែរឬទេ?

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសរួចជាស្រេចហើយនៅក្នុងច្បាប់និងកិច្ចព្រមព្រៀងថា ខ្លួននឹងមិនស្នើសុំការលើកលែងទោសឬការអនុគ្រោះទោសសម្រាប់ជនណាម្នាក់ ដែលត្រូវទទួលរងការស៊ើបអង្កេតឬត្រូវបានកាត់សេចក្តីថាមានទោសដោយអង្គជំនុំជម្រះវិសាមញ្ញទេ។



Sapordarmean Khmer (SPK)

*សវនាការដំបូងរបស់តុលាការប្រជាជនបដិវត្តន៍ ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៩*

## សំណួរទី ៦ តើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមណាខ្លះ ដែលត្រូវបានធ្វើការកាត់ក្តីរួចហើយ ?

នៅឆ្នាំ១៩៧៩ មានការកាត់ក្តីអំពើប្រល័យពូជសាសន៍នៅទីក្រុងភ្នំពេញ ដែលគេស្គាល់ថា ជាតុលាការប្រជាជនបដិវត្តន៍។ តុលាការនេះបានកាត់ទោស ប៉ុល ពត និង អៀង សារី ហើយបានរកឃើញថា ពួកគាត់ទាំងពីរជាប់ពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប៉ុន្តែអ្នកទាំងពីរមិនមានវត្តមាននៅចំពោះមុខតុលាការទេ ហើយក៏មិនបានទទួលទោសពីកំហុសដែលខ្លួនបានប្រព្រឹត្តនោះដែរ។

នៅឆ្នាំ១៩៩៦ ព្រះមហាក្សត្រនាពេលនោះ បានប្រទានការលើកលែងទោសចំពោះ អៀង សារី ដែលបានទទួលសាលក្រមប្រកាសដាក់ទោសដោយតុលាការប្រជាជនបដិវត្តន៍ ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាអ្នកសម្រេចទៅលើវិសាលភាពនៃការលើកលែងទោសនេះ។ បន្ថែមលើនេះទៀត ក៏អាចមានបទចោទប្រកាន់ផ្សេងៗទៀតដែលតុលាការអាចលើកឡើងប្រឆាំងនឹងគាត់។ វាអាស្រ័យទៅលើភ័ស្តុតាងដែលតុលាការអាចរកបាន។ នៅឆ្នាំ១៩៩៧ ក្រុមខ្មែរក្រហមខ្លួនឯងផ្ទាល់បានកាត់ទោស ប៉ុល ពត ពីបទឧក្រិដ្ឋដែលគាត់បានប្រព្រឹត្តនៅក្នុងរង្វង់អង្គការរបស់គាត់ក្រោយឆ្នាំ១៩៧៩។ ប៉ុល ពត ស្លាប់នៅឆ្នាំ១៩៩៨។ ដូច្នេះអង្គជំនុំជម្រះវិសាមញ្ញមិនអាចកាត់សេចក្តី ប៉ុល ពត បានទេ។

## សំណួរទី ៧ តើបណ្តាប្រទេសដែលធ្លាប់បានគាំទ្រ ឬក៏ជាប់ពាក់ព័ន្ធជាមួយកម្ពុជាប្រជាធិបតេយ្យ ឬក៏បណ្តាប្រទេសដែលប្រហែលជាបានប្រព្រឹត្តឧក្រិដ្ឋកម្មស្រង្គ្រាមនៅកម្ពុជាមុនឆ្នាំ ១៩៧៥ នឹងត្រូវកាត់ទោសដែរឬទេ ?

អត់ទេ។ អង្គជំនុំជម្រះវិសាមញ្ញអាចកាត់ក្តីតែបុគ្គលណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមតែប៉ុណ្ណោះ។ តុលាការនេះមិនអាចកាត់ក្តីប្រទេសឬអង្គការណាដទៃទៀតបានឡើយ។

## សំណួរទី ៨ តើនឹងមានការកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទថាបានប្រព្រឹត្តដោយមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ឬអ្នកដទៃទៀត ក្រោយឆ្នាំ ១៩៧៩ ដែរឬទេ ?

អត់ទេ។ តុលាការនេះកាត់សេចក្តីតែឧក្រិដ្ឋកម្មណាដែលបានប្រព្រឹត្តនៅកម្ពុជាក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៧៩ តែប៉ុណ្ណោះ។

ទោះជាយ៉ាងនេះក្តី តុលាការកម្ពុជាបច្ចុប្បន្នមានអំណាចនឹងកាត់ក្តីលើឧក្រិដ្ឋកម្មផ្សេងទៀត។ ឧទាហរណ៍ ការកាត់ក្តីនាយទាហានខ្មែរក្រហមដែលទទួលខុសត្រូវពីបទពួនស្ទាក់វាយប្រហារខ្សែរថភ្លើងពីភ្នំពេញទៅខេត្តកំពតនៅឆ្នាំ១៩៩៤ ដែលបានសម្លាប់ប្រជាជនកម្ពុជា ១១ នាក់ និងសម្លាប់ចំណាប់ខ្មាំងបស្ចិមប្រទេសបីនាក់ បានប្រព្រឹត្តទៅនៅក្នុងតុលាការក្នុងស្រុកដោយគ្មានជំនួយពីអង្គការសហប្រជាជាតិទេ។ ក្នុងករណីនេះ អតីតឧត្តមសេនីយ៍ខ្មែរក្រហមឈ្មោះ សំ ប៊ិត និង នួន ប៉ែត និងវរសេនីយ៍ឯក ឈូក រិន ត្រូវបានតុលាការរកឃើញថាជាប់ពិរុទ្ធ ហើយត្រូវកាត់ទោសឲ្យជាប់ពន្ធនាគារចំពោះបទល្មើសដែលគាត់បានប្រព្រឹត្ត។

## សំណួរទី ៩ តើតុលាការចាប់ផ្តើមជំនុំជម្រះក្តីនៅពេលណា?

ការជំនុំជម្រះក្តីលើកដំបូងប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច បានចាប់ផ្តើមនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ និងបានបញ្ចប់នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩។ នៅក្នុងអំឡុងរយៈពេល ៧៧ថ្ងៃ នៃការជំនុំជម្រះ សាក្សីជំនាញចំនួន ៩ នាក់ សាក្សីអង្គហេតុចំនួន ១៧ នាក់ សាក្សីផ្តល់សក្ខីកម្មអំពីអត្តចរិតរបស់ជនជាប់ចោទចំនួន ៧ នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២២ នាក់បានផ្តល់សក្ខីកម្ម។ សាលក្រមត្រូវបានប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។ សាលក្រមត្រូវបានប្តឹងសាទុក្ខដោយជនជាប់ចោទ សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះតុលាការកំពូលនឹងសម្រេចលើបណ្តឹងសាទុក្ខទាំងនេះនៅឆ្នាំ២០១១។

សហចៅក្រមស៊ើបអង្កេតបានបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ ហើយនៅខែកញ្ញា ឆ្នាំ២០១០ បានបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។ បុគ្គលដែលត្រូវបានចោទប្រកាន់និងបញ្ជូនទៅជំនុំជម្រះក្នុងសំណុំរឿងនេះមាន នួន ជា, ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ។ ការជំនុំជម្រះក្តីក្នុងសំណុំរឿងនេះត្រូវបានរំពឹងថានឹងចាប់ផ្តើមនៅឆមាសទី១ ឆ្នាំ២០១១។

នៅពេលនេះ វាមិនទាន់ច្បាស់នៅឡើយថាតើសំណើដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិសម្រាប់ធ្វើការស៊ើបសួរទាក់ទងជនសង្ស័យ ៥ រូបទៀតនឹងនាំឲ្យមានការជំនុំជម្រះក្តីបន្ថែមទៀតដែរឬយ៉ាងណានោះទេ។

មន្ត្រីនិងបុគ្គលិកតុលាការទាំងអស់ដឹងពីភាពបន្ទាន់នៃការជំនុំជម្រះក្តី និងកំពុងប្រឹងប្រែងធ្វើការដើម្បីបញ្ចប់ការងាររបស់ អ.វ.ត.ក ឲ្យបានលឿនតាមតែអាចធ្វើបាន និងស្របតាមបទដ្ឋានអន្តរជាតិ។

## សំណួរទី ១០ តើការជំនុំជម្រះក្តីនឹងប្រើរយៈពេលប៉ុន្មានឆ្នាំ?

រយៈពេលអាស្រ័យថាតើអ្នកស៊ើបអង្កេតត្រូវការរយៈពេលប៉ុន្មាន ដើម្បីប្រមែប្រមូលភស្តុតាង តើមានមនុស្សប៉ុន្មាននាក់នឹងត្រូវយកមកកាត់ទោស តើមានសាក្សីប៉ុន្មាននាក់នឹងត្រូវអញ្ជើញមកបំភ្លឺនៅតុលាការ ហើយថាតើនឹងមានការប្តឹងឧទ្ធរណ៍ប៉ុន្មានករណី។ នៅពេលដែលការជំនុំជម្រះនិងការប្តឹងឧទ្ធរណ៍បានចប់សព្វគ្រប់ អ.វ.ត.ក នឹងត្រូវរំលាយខ្លួនជាស្វ័យប្រវត្តិ។



រូបថតៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

*សាលសវនាការនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា*

**សំណួរទី ១១** តើការជំនុំជម្រះក្តីនេះកំពុងប្រព្រឹត្តទៅនៅកន្លែងណា?

ការកាត់ក្តីនេះកំពុងប្រព្រឹត្តទៅនៅសាលសវនាការដ៏ធំមួយដែលស្ថិតនៅជាយក្រុងភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ ៤ ក្នុងសង្កាត់ចោមចៅ ខណ្ឌដង្កោ។

**សំណួរទី ១២** តើអង្គជំនុំជម្រះវិសាមញ្ញធ្វើការរបៀបដូចម្តេច?

តុលាការវិសាមញ្ញមានពីរកម្រិតគឺ សាលាដំបូង និង តុលាការកំពូល។ សាលាដំបូងមានចៅក្រមចំនួន ៥ រូប ក្នុងនោះមានចៅក្រមកម្ពុជា ៣ រូប និង ចៅក្រមអន្តរជាតិ ២ រូប។ តុលាការកំពូលមានចៅក្រមចំនួន ៧ រូប ក្នុងនោះមានចៅក្រមកម្ពុជា ៤ រូប និងចៅក្រមអន្តរជាតិ ៣ រូប។

តុលាការកំពូលចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ។ រាល់សេចក្តីសម្រេចរបស់តុលាការកំពូលជាសេចក្តីសម្រេចស្ថាពរ និងបិទផ្លូវតវ៉ា។

តុលាការកំពូល
មានចៅក្រម ៧ រូប : ខ្មែរ ៤ អន្តរជាតិ ៣

↑

ការប្តឹងឧទ្ធរណ៍ឡើងតុលាការកំពូល

សាលាដំបូង
មានចៅក្រម ៥ រូប : ខ្មែរ ៣ អន្តរជាតិ ២

អង្គបុរេជំនុំជម្រះ
មានចៅក្រម ៥ រូប : ខ្មែរ ៣ អន្តរជាតិ ២

អង្គបុរេជំនុំជម្រះមានភារកិច្ចទទួលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងរាល់សកម្មភាពដែលកើតឡើងនៅមុនពេលជំនុំជម្រះអង្គសេចក្តី ដូចជាការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចឃុំខ្លួនបណ្តោះអាសន្នជាដើម។ អង្គបុរេជំនុំជម្រះនឹងដោះស្រាយបញ្ហាទាំងឡាយដូចមានរៀបរាប់នៅក្នុងសំណួរទី១៨ ខាងក្រោមដែរ។



រូបថត: មជ្ឈមណ្ឌលឯកសារកម្ពុជា

*ប្រជាជនតម្រង់ជួរនៅមុខច្រកចូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីចូលរួមស្តាប់សវនាការសាធារណៈ*

## សំណួរទី ១៣ តើអ្នកណាខ្លះអាចចូលទៅស្តាប់ការកាត់ក្តីបាន ?

ការកាត់ក្តីនេះគឺសម្រាប់ប្រជាជនកម្ពុជា។ បុគ្គលគ្រប់រូបដែលមានអាយុចាប់ពី១៨ឆ្នាំ រួមទាំងជនបរទេសផង អាចចូលស្តាប់ការកាត់ក្តីនេះបាន។ គ្មានការបង់ប្រាក់ដើម្បីចូលស្តាប់សវនាការឡើយ ហើយមានកៅអីរាប់រយដែលត្រៀមបម្រុងទុកសម្រាប់សាធារណជនទូទៅ ។

រាល់សវនាការទាំងអស់នឹងបើកចំហជូនសាធារណជនគ្រប់ពេលវេលា លើកលែងតែក្នុងស្ថានការណ៍ពិសេសនៅពេលដែលចៅក្រមសម្រេចថា ត្រូវហាមឃាត់មិនឲ្យមានវត្តមានសាធារណជន ដើម្បីការពារអត្តសញ្ញាណរបស់សាក្សី ឬជនរងគ្រោះ។

បច្ចុប្បន្ននេះ តុលាការផ្តល់រថយន្តក្រុងដឹកជញ្ជូនជាក្រុមដល់ប្រជាជនកម្ពុជាដែលចង់ធ្វើទស្សនកិច្ចនៅតុលាការ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងផ្នែកកិច្ចការសាធាណៈ តាមរយៈទូរស័ព្ទលេខ ០២៣ ២១៩ ៨១៤ ឬសារអេឡិចត្រូនិក pas@eccc.gov.kh ។

## សំណួរទី ១៤ ប្រសិនបើយើងមិនអាចចូលទៅស្តាប់ការកាត់ក្តីនេះដោយផ្ទាល់បាន តើធ្វើដូចម្តេចយើងអាចដឹងបានពីអ្វីដែលកំពុងកើតឡើងនៅក្នុងតុលាការ ?

ប្រជាជនទូទាំងពិភពលោកចង់ដឹងអំពីសកម្មភាពឬព័ត៌មានដែលកំពុងកើតឡើងនៅក្នុងសវនាការជំនុំជម្រះក្តី។ លោកអ្នកអាចតាមដានព្រឹត្តិការណ៍ទាំងនោះបានតាមរយៈវិទ្យុ ទូរទស្សន៍ និងបណ្តាញសារព័ត៌មាន ជាតិនិងអន្តរជាតិ។

អ.វ.ត.ក ចែកចាយព័ត៌មានអំពីតុលាការនេះនៅទូទាំងប្រទេសកម្ពុជា រួមមានការចែកចាយកូនសៀវភៅនេះ ផ្ទាំងបិទផ្សាយព័ត៌មាន ស្លាកបិទផ្សាយព័ត៌មាន និងសម្ភារៈឬឯកសារផ្សព្វផ្សាយដទៃទៀត។ ក្រៅពីនេះ អង្គការក្រៅរដ្ឋាភិបាលជាច្រើន បានបង្កើតកម្មវិធីផ្សព្វផ្សាយក្នុងគោលបំណងជួយឲ្យប្រជាជនកម្ពុជាយល់ដឹងអំពីដំណើរការកាត់ក្តីរបស់ អ.វ.ត.ក។

សាកលវិទ្យាល័យ Northwestern នៅសហរដ្ឋអាមេរិក បានបញ្ចូលវីដេអូអំពីដំណើរការសវនាការរបស់សាលាក្តីនៅក្នុងគេហទំព័ររបស់ខ្លួនឈ្មោះ www.cambodiatribunal.org ដែលអាចបើកមើលវីដេអូអំពីដំណើរការសវនាការ។

## សំណួរទី ១៥ តើចៅក្រមត្រូវបានតែងតាំងឡើងយ៉ាងដូចម្តេច ?

អគ្គលេខាធិការអង្គការសហប្រជាជាតិបានជ្រើសតាំងចៅក្រមអន្តរជាតិមួយចំនួន។ នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៦ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាបានជ្រើសរើសចេញពីបញ្ជី នូវឈ្មោះចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិចំនួន១២ រូបដែលមកពីប្រទេស ១០ ផ្សេងៗគ្នា។ ស្របពេលជាមួយគ្នានោះដែរ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក៏បានជ្រើសរើសចៅក្រមនិងព្រះរាជអាជ្ញាកម្ពុជាចំនួន១៧ រូប។ ចៅក្រមនិងព្រះរាជអាជ្ញាទាំង ២៩ រូបនេះ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៦។ ចៅក្រមនិងព្រះរាជអាជ្ញាទាំងអស់បានស្បថនៅក្នុងវិហារព្រះកែវមរកតនៅរាជធានីភ្នំពេញ។ នីតិវិធីដូចគ្នាត្រូវអនុវត្តនៅពេលមានតម្រូវការតែងតាំងចៅក្រមថ្មី។

ក្នុងការជ្រើសរើសនេះ ទាំងចៅក្រមកម្ពុជានិងចៅក្រមអន្តរជាតិត្រូវតែមានចរិយាសម្បត្តិថ្លៃថ្នូរ អាស្រ័យទៅតាមចរិតលក្ខណៈប្រទេសរបស់ពួកគាត់ផ្ទាល់។ អ្នកទាំងនោះត្រូវតែស្មោះត្រង់ និងឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន។ ពួកគាត់មិនត្រូវទទួលការបង្គាប់បញ្ជាពីជនណាមួយ ពីរាជរដ្ឋាភិបាល ឬពីប្រភពណាមួយផ្សេងទៀតឡើយ។ ចៅក្រមទាំងអស់បានទទួលការបណ្តុះបណ្តាលច្បាស់លាស់អំពីច្បាប់ជាតិនិងច្បាប់អន្តរជាតិ ព្រមទាំងពីនីតិវិធីទាំងឡាយដែលពាក់ព័ន្ធនឹងកិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

## សំណួរទី ១៦ តើអង្គចៅក្រមនឹងឈានដល់ការចេញសេចក្តីសម្រេចយ៉ាងដូចម្តេច ?

នៅក្នុងដំណើរការអង្គជំនុំជម្រះវិសាមញ្ញ ចៅក្រមទាំងអស់នឹងព្យាយាមសម្រេចឲ្យបាននូវការព្រមព្រៀងគ្នាជាឯកច្ឆន្ទទៅលើរាល់ការសម្រេច ឬសាលក្រមណាមួយដែលបានធ្វើឡើង។ ប្រសិនបើ ចៅក្រមមិនយល់ព្រមទាំងស្រុងនោះទេ សេចក្តីសម្រេចនឹងត្រូវធ្វើឡើងដោយសំឡេង "ភាគច្រើនលើសលប់"។

នៅសាលាដំបូង ត្រូវតែមានចៅក្រម៤រូបក្នុងចំណោមចៅក្រម ៥ រូប បោះឆ្នោតយល់ព្រមសម្រេចសេចក្តីឲ្យជាប់ទោស ហើយនៅតុលាការកំពូលត្រូវតែមានចៅក្រម៥រូបក្នុងចំណោមចៅក្រម ៧ រូប បោះឆ្នោតយល់ព្រមទៅលើសេចក្តីសម្រេចឬសាលដីកាស្ថាពរលើបណ្តឹងឧទ្ធរណ៍។ ដូច្នេះ រាល់សេចក្តីសម្រេចត្រូវតែមានការគាំទ្រទាំងចៅក្រមកម្ពុជានិងចៅក្រមអន្តរជាតិ។ ដោយផ្អែកតាមរូបមន្តនេះ ប្រសិនបើពុំមានសំឡេង "ភាគច្រើនលើសលប់" ទេនោះ ចុងចោទនឹងត្រូវបានដោះលែង។ នេះគឺអនុលោមទៅតាមមូលដ្ឋានគ្រឹះនៃគោលការណ៍ច្បាប់ដែលចែងថា អ្នកណាក៏ដោយ ត្រូវបានចាត់ទុកថាគ្មានទោសរហូតទាល់តែអ្នកនោះត្រូវបានកាត់ទោស ហើយរកឃើញកំហុសពីបទឧក្រិដ្ឋណាមួយ។




រូបថត: មជ្ឈមណ្ឌលឯកសារកម្ពុជា

*ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសវនាការថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលជាសវនាការចុងក្រោយបង្អស់នៃសំណុំរឿង ០០១*

## សំណួរទី ១៧ តើអ្នកណាជាអ្នកសម្រេចថាជនណាខ្លះនឹងត្រូវកាត់សេចក្តី? តើអ្នកណាជាអ្នកសម្រេចថាពួកគេនឹងត្រូវចោទប្រកាន់ពីបទល្មើសអ្វី?

អង្គជំនុំជម្រះវិសាមញ្ញមានសហព្រះរាជអាជ្ញាពីររូប (កម្ពុជាមួយរូប និងអន្តរជាតិមួយរូប) ជាអ្នករៀបចំបញ្ជីឈ្មោះជនសង្ស័យ និងប្រមូលភ័ស្តុតាងបឋមនៃបទឧក្រិដ្ឋដែលត្រូវបានចោទថាបានប្រព្រឹត្ត ។ សហព្រះរាជអាជ្ញានឹងបញ្ជូនសំណុំរឿងក្តីទៅសហចៅក្រមស៊ើបអង្កេតពីររូប (កម្ពុជាមួយរូប និងអន្តរជាតិមួយរូប)។ សហចៅក្រមស៊ើបអង្កេតនឹងពិនិត្យពិច័យព័ត៌មានដែលទទួលបានពីសហព្រះរាជអាជ្ញា និងអនុវត្តកិច្ចស៊ើបសួរដោយឯករាជ្យនិងមិនលម្អៀង មុននឹងធ្វើការសម្រេចចោទប្រកាន់។

ប្រសិនបើការស៊ើបអង្កេតបង្ហាញភ័ស្តុតាងគ្រប់គ្រាន់ តុលាការនឹងបន្តជំនុំជម្រះក្តីលើសំណុំរឿងនោះ។

## សំណួរទី ១៨ តើនឹងមានអ្វីកើតឡើង ប្រសិនបើសហព្រះរាជអាជ្ញា ឬក៏សហចៅក្រមស៊ើបអង្កេតមិនយល់ស្របគ្នា ថាតើត្រូវបញ្ជូនឬមិនបញ្ជូនរឿងក្តីទៅជំនុំជម្រះ?

ទាំងសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត នឹងព្យាយាមសម្រេចឲ្យបាននូវការព្រមព្រៀងគ្នា ប៉ុន្តែប្រសិនបើពួកគាត់មិនអាចឈានដល់ការឯកភាពគ្នានោះទេ ពេលនោះចៅក្រម ៥ រូប មកពីអង្គបុរេជំនុំជម្រះនឹងជួបជុំគ្នាដើម្បីធ្វើការសម្រេចថាតើត្រូវបញ្ជូនឬមិនបញ្ជូនរឿងក្តីទៅជំនុំជម្រះ។ ចៅក្រមឬសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត កម្ពុជាតែឯង ឬអន្តរជាតិតែឯង មិនអាចធ្វើឲ្យរាំងស្ទះដល់ការបញ្ជូនរឿងក្តីណាមួយទៅកាត់សេចក្តីបានឡើយ។

សំណួរទី ១៩

## តើចៅក្រមនៅសាលាដំបូងធ្វើការងារអ្វីខ្លះ ?

ចៅក្រមនៅសាលាដំបូងនឹងពិនិត្យភ័ស្តុតាងដែលលើកឡើងដោយព្រះរាជអាជ្ញា ដោយមេធាវីចុងចោទ និងដោយជនរងគ្រោះដែលជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ បន្ទាប់មកចៅក្រមនឹងពិចារណាលើសេចក្តីថ្លែងការណ៍ទាំងសងខាង រួចធ្វើការពិភាក្សាសម្រេចចិត្តថាតើជនសង្ស័យមានជាប់ពិរុទ្ធឬក៏អត់ ។ ចៅក្រមកាត់ក្តីត្រូវចេញសេចក្តីវិនិច្ឆ័យ ឬសាលក្រមមួយជាលាយលក្ខណ៍អក្សរពន្យល់ពីហេតុផលនៃការវិនិច្ឆ័យដែលបានធ្វើឡើង ។ ប្រសិនបើមានចៅក្រមណាម្នាក់មិនឯកភាពនឹងសាលក្រមនោះទេ ចៅក្រមនោះមានតួនាទីពន្យល់អំពីហេតុផលដែលនាំឲ្យខ្លួនបោះឆ្នោតផ្សេងពីមតិភាគច្រើន ។ រាល់ការវិនិច្ឆ័យឬសាលក្រមទាំងអស់ត្រូវផ្សព្វផ្សាយជាសាធារណៈ ។



*ប្រព័ន្ធកាត់ក្តីនៅតុលាការនាសម័យអង្គរត្រូវបានប្រើប្រាស់ជាមូលដ្ឋាននៃបដិរូប តំណាងឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ រូបចម្លងចេញពីគំនូរ លើជញ្ជាំងនៃអគារតុលាការកំពូលនៅក្រសួងយុត្តិធម៌ ។*



## បដិរូបជាផ្លូវការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បដិរូបតំណាងឲ្យអង្គជំនុំជម្រះដោយមានការពិពណ៌នារួមមួយនៃការគ្រប់គ្រងនៃតុលាការកម្ពុជាក្នុងសម័យបុរាណអង្គរ និងអមដោយក្នួរផ្លែអូលីវ ជាសញ្ញារបស់អង្គការសហប្រជាជាតិដែលតំណាងឲ្យសន្តិភាព ។ ពណ៌ជាផ្លូវការគឺពណ៌ខៀវចាស់ ។

រូបអង្គុយលើបល្ល័ង្ក ហើយកាន់ដាវមួយតំណាងឲ្យអំណាចតុលាការ ។ វាគឺជារូបតាំងលើជញ្ជាំងកណ្តាលគេ នៅអតីតសាលាឧទ្ធរណ៍ក្នុងក្រសួងយុត្តិធម៌នៅទីក្រុងភ្នំពេញ ។ រូបនោះអមដោយអ្នកជំនួយការពីរនាក់ដែលកំពុងអានច្បាប់ដែលចារដោយដៃលើស្លឹករឹត ។

## សំណួរទី ២០ តើភ័ស្តុតាងអ្វីខ្លះនឹងត្រូវប្រើប្រាស់នៅពេលកាត់សេចក្តី?

ភ័ស្តុតាងនឹងត្រូវបង្ហាញជូនដោយចៅក្រមអង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញា ក្រុមមេធាវីការពារក្តី និងមេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី។ ភ័ស្តុតាងទាំងនេះអាចជា៖

- ឯកសារ
- ភ័ស្តុតាងរូបវ័ន្ត ដូចជារណ្តៅសាកសពរួម ឬក៏អតីតគុក និង
- សេចក្តីថ្លែងការណ៍ និងកសិណសាក្សីជាជនរងគ្រោះ ឬជនដែដល់ សាក្សី និងចុងចោទ

ឯកសាររាប់ពាន់សន្លឹកត្រូវបានប្រមូលចងក្រងទុក ហើយរណ្តៅសាកសពរួម គុក និង បូជនីយដ្ឋានរាប់រយកន្លែង ត្រូវបានគេទៅពិនិត្យមើល និងផែនទីជាច្រើនត្រូវបានគូរដោយគណៈកម្មាធិការស្រាវជ្រាវរបស់រណសិរ្ស និងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងដោយកម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជា។ ភ័ស្តុតាងទាំងអស់នោះត្រូវបានផ្តល់ទៅឲ្យអង្គជំនុំជម្រះវិសាមញ្ញរួចហើយ។

នៅក្នុងតុលាការកម្ពុជា គ្រប់ភ័ស្តុតាងទាំងអស់ដែលប្រមូលបានដោយត្រឹមត្រូវតាមនីតិវិធីច្បាប់ អាចយកមកពិចារណាបាន។ វាអាស្រ័យទៅលើចៅក្រមជាអ្នកសម្រេចអំពីសារសំខាន់នៃភ័ស្តុតាងនីមួយៗ។

## សំណួរទី ២១ តើបទឧក្រិដ្ឋអ្វីនឹងត្រូវធ្វើការកាត់ក្តី? តើការកាត់ក្តីប្រើច្បាប់កម្ពុជាឬច្បាប់អន្តរជាតិ?

ប្រជាជនចំនួនយ៉ាងហោចណាស់១,៧ លាននាក់បានស្លាប់ដោយការធ្វើទារុណកម្ម ការប្រហារជីវិត ការអត់ឃ្លាន និងជំងឺដែលមិនមានការព្យាបាលចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ចៅក្រមចាំបាច់ត្រូវធ្វើការសម្រេចចិត្តឲ្យបានច្បាស់លាស់ អំពីបទឧក្រិដ្ឋអ្វីដែលត្រូវបានប្រព្រឹត្តនៅពេលនោះ និងដោយអ្នកណាខ្លះ។ ការប្រឈមមុខនឹងការកាត់សេចក្តីនេះ នឹងអាស្រ័យទៅលើការប្រមែប្រមូលភ័ស្តុតាងឲ្យបានគ្រប់គ្រាន់ ដើម្បីរកឲ្យឃើញនូវទោសកំហុសរបស់បុគ្គលណាមួយដែលបានប្រព្រឹត្តបទឧក្រិដ្ឋ។

ទាំងបទឧក្រិដ្ឋនៅក្រោមច្បាប់ជាតិនិងច្បាប់អន្តរជាតិ អាចត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក។ បទឧក្រិដ្ឋជាក់លាក់ត្រូវបានរៀបរាប់ខាងក្រោម៖

### បទឧក្រិដ្ឋនៅក្រោមច្បាប់របស់កម្ពុជា រួមមាន ៖

- អំពើមនុស្សឃាដ
- ការធ្វើទារុណកម្ម
- ការធ្វើទុក្ខបុកម្នេញខាងសាសនា

### បទឧក្រិដ្ឋនៅក្រោមច្បាប់របស់អន្តរជាតិ រួមមាន ៖

- **អំពើប្រល័យពូជសាសន៍**
  ការសម្លាប់រង្គាល ឬធ្វើឲ្យខូចខាត បាត់បង់ដោយចេតនា បំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធ ពូជសាសន៍ ឬសាសនាណាមួយ។

- **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**
  ដូចជា អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ និងបទឧក្រិដ្ឋផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទ។
- **អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩**
  ដូចជាការប្រព្រឹត្តដោយខុសច្បាប់ទៅលើជនស៊ីវិល ឬឈ្លើយសឹក ការវាយប្រហារលើគោលដៅជនស៊ីវិល និងការបំផ្លាញស្ថាប័នអប់រំនិងសាសនា។
- **ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌**
  ដូចជាការលួចឬបំផ្លិចបំផ្លាញអគារប្រវត្តិសាស្ត្រ ទីតាំងបុរាណវិទ្យា សារមន្ទីរ ស្នាដៃសិល្បៈឬប្រវត្តិសាស្ត្រ សៀវភៅសំខាន់ៗ និងបណ្ណាល័យ។
- **ឧក្រិដ្ឋកម្មប្រឆាំងមនុស្ស**ដែលត្រូវបានការពារដោយច្បាប់អន្តរជាតិ (មន្ត្រីទូត)។

## សំណួរទី ២២ តើចុងចោទមានសិទ្ធិអ្វីខ្លះ?

ចុងចោទ (ជនត្រូវចោទ និងជនជាប់ចោទ) មានសិទ្ធិការពារខ្លួននៅក្រោមច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ។ សិទ្ធិខ្លះនៃសិទ្ធិទាំងអស់នោះមាន៖

- សិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវនិងជាសាធារណៈ
- សិទ្ធិត្រូវបានគេសន្មតថាមិនមានកំហុស រហូតទាល់តែត្រូវបានតុលាការកាត់សេចក្តីថាមានទោស



*កៅអីទាំង៥០០នៃសាលសវនាការនេះមានអ្នកចូលរួមអង្គុយពេញជាប្រចាំ នៅរៀងរាល់សវនាការ។ នេះគឺជាសាលសវនាការ*

- សិទ្ធិជួលមេធាវីទៅតាមការជ្រើសរើសរបស់ខ្លួន ទោះជាមេធាវីមានសញ្ជាតិខ្មែរឬបរទេស
- សិទ្ធិមានពេលវេលានិងសម្ភារៈគ្រប់គ្រាន់ដើម្បីឲ្យមេធាវីរៀបចំការពារក្តី
- សិទ្ធិទទួលបានមេធាវីពីសាលាក្តីខ្មែរក្រហម ប្រសិនបើចុងចោទមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីចំណាយទៅលើការជួលមេធាវី
- សិទ្ធិត្រួតពិនិត្យសាក្សីដែលបានចោទប្រកាន់ទៅលើរូបគាត់។



រូបថត: មជ្ឈមណ្ឌលឯកសារកម្ពុជា

*ធំបំផុតក្នុងចំណោមសាលសវនាការរបស់តុលាការអន្តរជាតិទាំងអស់នៅលើពិភពលោកដែលគាំទ្រដោយអង្គការសហប្រជាជាតិ*

### សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវនិងយុត្តិធម៌

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ អនុវត្តបានចំពោះសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លើកបង្ហាញពីសិទ្ធិនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលត្រូវបានអនុវត្តនៅ អ.វ.ត.ក ដូចជាសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌និងមិនលម្អៀង រួចផុតពីការជ្រៀតជ្រែកនយោបាយ សិទ្ធិនៃការសន្មតថាគ្មានទោសរហូតដល់តុលាការកាត់ឲ្យមានទោស និងសិទ្ធិទទួលបានមេធាវីតំណាងផលប្រយោជន៍។

## សំណួរទី ២៣ តើអ្នកណាខ្លះនឹងត្រូវកោះអញ្ជើញឲ្យធ្វើជាសាក្សី?

សាក្សីគឺជាមនុស្សដែលអាចផ្តល់ព័ត៌មាន ឬរឿងរ៉ាវដោយផ្ទាល់និងពិតប្រាកដទាក់ទងនឹងការស៊ើបអង្កេត និងការកាត់ក្តីនានាដែលស្ថិតនៅក្នុងអាណត្តិរបស់តុលាការ។ អ្នកទាំងនោះអាចជាជនរងគ្រោះ ឬជាមនុស្សណាម្នាក់ដែលមានព័ត៌មានទាក់ទងបទឧក្រិដ្ឋនោះ។ រឿងរ៉ាវជាក់ស្តែងដែលបុគ្គលនោះរៀបរាប់

មានតម្លៃស្មើនឹងភ័ស្តុតាង។ ភ័ស្តុតាងដែលផ្តល់ដោយសាក្សីក្នុងអំឡុងពេលស៊ើបអង្កេត នឹងក្លាយទៅជាផ្នែកមួយនៃសំណុំរឿង ឬប្រសិនបើត្រូវបានផ្តល់ឲ្យក្នុងពេលកាត់ក្តី ភ័ស្តុតាងនោះនឹងក្លាយទៅជាឯកសារផ្លូវការនៃសវនាការ។ អ្នកណាក៏ដោយដែលត្រូវចាត់ទុកថាជាមនុស្សសំខាន់សម្រាប់ផ្តល់ការពិតក្នុងពេលស៊ើបអង្កេតនិងពេលកាត់ក្តី អាចនឹងត្រូវសុំឲ្យផ្តល់ភ័ស្តុតាង រាប់បញ្ចូលទាំងអ្នកជំនាញផងដែរ។

## សំណួរទី ២៤ តើខ្ញុំត្រូវផ្តល់ព័ត៌មានទៅឲ្យតុលាការដែរឬទេ?

ប្រសិនបើព្រះរាជអាជ្ញាឬចៅក្រមស៊ើបអង្កេតចង់សម្ភាសន៍ជាមួយលោកអ្នកក្នុងករណីនេះ លោកអ្នកត្រូវតែនិយាយការពិត។ ទោះជាយ៉ាងណាក៏ដោយលោកអ្នកមានសិទ្ធិនៅស្ងៀម ប្រសិនបើលោកអ្នកយល់ថាចម្លើយអាចធ្វើឲ្យលោកអ្នកមានជាប់ទាក់ទិននៅក្នុងបទឧក្រិដ្ឋនោះ។ ហើយលោកអ្នកមានសិទ្ធិស្នើសុំមេធាវី (ស្នាក្តី) ដើម្បីផ្តល់ការប្រឹក្សាដល់លោកអ្នក និងស្ថិតនៅជាមួយលោកអ្នកនៅក្នុងពេលចោទសំណួរ។ (សម្រាប់ព័ត៌មានលម្អិត សូមអានទំព័រ *ប្រភពព័ត៌មាន*)។

## សំណួរទី ២៥ តើធ្វើយ៉ាងដូចម្តេចប្រសិនបើខ្ញុំចង់ផ្តល់ព័ត៌មានអំពីនរណាមួយដែលខ្ញុំជឿជាក់ថាបានប្រព្រឹត្តបទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរក្នុងអំឡុងរបបខ្មែរក្រហម?

ប្រសិនបើអ្នកមានព័ត៌មានដែលអ្នកគិតថាវាអាចជួយដល់ព្រះរាជអាជ្ញា ឬអ្នកការពារក្តី ពេលនោះអ្នកអាចទាក់ទងដោយផ្ទាល់ខ្លួននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬតាមរយៈអង្គការអន្តរការី (សម្រាប់ព័ត៌មានលម្អិត សូមអានទំព័រ *ប្រភពព័ត៌មាន*)។ ជនរងគ្រោះនិងអ្នកផ្សេងទៀតដែលមានព័ត៌មានទាក់ទិន អាចផ្ញើព័ត៌មាននេះទៅតុលាការ។ ដើម្បីឲ្យសម្រេចបាននូវគោលបំណង លោកអ្នកគួរតែបំពេញព័ត៌មាននេះចូលទៅទម្រង់បែបបទព័ត៌មានសម្រាប់ជនរងគ្រោះ ហើយដាក់ជូនទៅអង្គភាពគាំពារជនរងគ្រោះ។ (សូមអានសំណួរទី២៧ សម្រាប់ព័ត៌មានបន្ថែម)

## សំណួរទី ២៦ តើការគាំទ្រអ្វីខ្លះនឹងត្រូវផ្តល់ទៅឲ្យសាក្សីនិងជនរងគ្រោះដែលផ្តល់សក្ខីកម្ម និងសម្រាប់មនុស្សទូទាំងប្រទេសដែលអាចនឹងមានការឈឺចាប់ក្នុងចិត្តនៅពេលស្តាប់ឮសក្ខីកម្មដែលបានបង្ហាញនៅក្នុងតុលាការ?

សាក្សីអាចទទួលរងការឈឺចាប់ក្នុងអារម្មណ៍នៅពេលផ្តល់សក្ខីកម្មអំពីបទពិសោធន៍របស់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូច្នេះតុលាការរៀបចំផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រដល់សាក្សីទាំងឡាយ។ បុគ្គលដែលមិនត្រូវផ្តល់សក្ខីកម្ម ប៉ុន្តែត្រូវការការពិគ្រោះយោបល់និងការព្យាបាល គប្បីទាក់ទងគណៈកម្មាធិការសុខភាពផ្លូវចិត្តរបស់ក្រសួងសុខាភិបាលដែលមានការិយាល័យនៅតាមបណ្តាខេត្តនានាទូទាំងប្រទេស ឬអង្គការក្រៅរដ្ឋាភិបាលដែលជំនាញឯកទេសផ្នែកនេះ ដូចជាកម្មវិធីសុខភាពផ្លូវចិត្ត អង្គការចិត្តសង្គម-អន្តរវប្បធម៌ (TPO) និងសេវាសង្គមកិច្ចកម្ពុជា (SSC)។ (សម្រាប់ព័ត៌មានលម្អិត សូមអានទំព័រ *ប្រភពព័ត៌មាន*)។



រូបថត: មជ្ឈមណ្ឌលឯកសារកម្ពុជា

*អ្នករស់រានមានជីវិតពីគុកទួលស្លែង លោកអ៊ំ វ៉ាន់ ណាត (ខាងស្តាំ) និងលោកអ៊ំ ជុំម៉ី (ខាងឆ្វេង) លើកសៀវភៅសាលក្រមក្នុងសំណុំរឿង ០០១ ប្រឆាំងនឹងអតីតប្រធានគុកឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច*

## សំណួរទី ២៧ តើជនរងគ្រោះអាចចូលរួមក្នុងសវនាការយ៉ាងដូចម្តេច?

ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងទៅសហព្រះរាជអាជ្ញានូវបទឧក្រិដ្ឋទាំងឡាយដែលពួកគាត់ជឿថាត្រូវបានប្រព្រឹត្ត។

ជនរងគ្រោះដែលទទួលការឈឺចាប់ទាំងផ្លូវកាយ ផ្លូវចិត្ត និងខូចខាតសម្ភារៈដោយសារតែឧក្រិដ្ឋកម្មដែលស៊ើបអង្កេតដោយតុលាការ អាចដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការជ្រើសរើសមេធាវីរបស់ខ្លួន។ បើសិនត្រូវការជំនួយ អ.វ.ត.ក នឹងជួយពួកគាត់ក្នុងការរៀបចំតំណាងរួមផ្នែកច្បាប់។ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចរៀបចំសកម្មភាពរបស់ខ្លួនដោយចូលជាសមាជិកនៃសមាគមជនរងគ្រោះ។ (សម្រាប់ព័ត៌មានលម្អិតសូមអានទំព័រ *ប្រភពព័ត៌មាន*)។

ជនរងគ្រោះដែលចង់ចូលរួមក្នុងដំណើរការដោយធ្វើជាអ្នកប្តឹង ឬដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបំពេញទម្រង់បែបបទព័ត៌មានជនរងគ្រោះ ហើយផ្ញើទៅអង្គភាពគាំពារជនរងគ្រោះ។ សូមកត់សម្គាល់ផងដែរថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០២ បានបិទនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ ប៉ុន្តែលោកអ្នកនៅតែអាចដាក់ពាក្យបណ្តឹងបានគ្រប់ពេល។

ទម្រង់បែបបទនៃពាក្យបណ្តឹង ក៏អាចសុំពីអង្គភាពគាំពារជនរងគ្រោះតាមអាស័យដ្ឋានខាងក្រោម។

ទម្រង់បែបបទនេះ ក៏អាចទទួលយកបានពីក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.eccc.gov.kh និងត្រូវបានចែកចាយដល់បណ្តាអង្គការដៃគូនានា ដូចដែលមានបញ្ជាក់នៅផ្នែកខាងក្រោយនៃកូនសៀវភៅនេះ។

**អង្គភាពគាំពារជនរងគ្រោះ**
ផ្ទះលេខ៦A ផ្លូវ ២១ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
ភ្នំពេញ(នៅជិតផ្សារកាប់គោ)
ទូរស័ព្ទ: (៨៥៥) ២៣ ២១៤ ២៩១
ឬ ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ២១៩ ៨១៤

## ការចូលរួមរបស់ជនរងគ្រោះ

អង្គភាពគាំពារជនរងគ្រោះត្រូវបានបង្កើតឡើងដើម្បីជួយជនរងគ្រោះដែលចង់ចូលរួមក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះ។ អង្គភាពគាំពារជនរងគ្រោះគឺជាមជ្ឈមណ្ឌលកណ្តាលសម្រាប់ទាក់ទងរវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជនរងគ្រោះ ឬតំណាងរបស់ពួកគាត់។ អង្គភាពគាំពារជនរងគ្រោះត្រូវផ្តល់ព័ត៌មានជូនដល់ជនរងគ្រោះ អំពីសិទ្ធិរបស់ពួកគាត់ក្នុងការចូលរួមនិងការទទួលសំណង និងជួយដល់ពួកគាត់ក្នុងការសរសេរពាក្យបណ្តឹងនិងទម្រង់បែបបទសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីផ្ញើទៅ អ.វ.ត.ក ប្រសិនបើពួកគាត់ចង់ធ្វើដូច្នេះ។ អង្គភាពគាំពារជនរងគ្រោះជួយគាំទ្រដល់ការងាររបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ដោយរៀបចំបែបបទធ្វើពាក្យបណ្តឹង និងពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី។ ក្រៅពីនេះ អង្គភាពក៏ជួយរក្សាទំនាក់ទំនងរវាងជនរងគ្រោះនិងមេធាវីរបស់គាត់លើការងារទាក់ទងនឹងពាក្យបណ្តឹងនិងពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី និងជួយផ្តល់ព័ត៌មានទាន់ហេតុការណ៍នានាទាក់ទិននឹងការវិវឌ្ឍនៃរឿងក្តីនីមួយៗ។ អង្គភាពនេះក៏នឹងជួយដល់ជនរងគ្រោះ ដើម្បីទទួលបានការសេវាកម្មផ្នែកច្បាប់ក៏ដូចជាការគាំទ្រផ្លូវចិត្តជាដើម។

## សំណួរទី ២៨ តើជនរងគ្រោះមានសិទ្ធិទទួលសំណងដែរឬទេ ?

ប្រសិនបើជនជាប់ចោទត្រូវបានផ្តន្ទាទោសដោយ អ.វ.ត.ក ជនរងគ្រោះអាចស្នើសុំទៅតុលាការឲ្យចេញដីកាបង្គាប់ឲ្យមានការសងសំណង។

នៅក្រោមច្បាប់កម្ពុជាបច្ចុប្បន្ន ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចទាមទារសំណងក្នុងករណីបណ្តឹងព្រហ្មទណ្ឌដែលពួកគាត់ទទួលរងពីបទឧក្រិដ្ឋ។ ចៅក្រមបានសម្រេចថា អង្គជំនុំជម្រះវិសាមញ្ញមិនអាចផ្តល់សំណងជាសាច់ប្រាក់បានឡើយ ដោយហេតុថាមានជនរងគ្រោះច្រើនលើសលប់ ប៉ុន្តែជនរងគ្រោះអាចទទួលបានសំណងតាមរូបភាពជារួម និងសំណងជាការគាំទ្រខាងផ្លូវចិត្ត ដូចជា ការសម្រេចតម្រូវឲ្យផ្សាយសេចក្តីសម្រេចស្តីអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជនតាមរយៈសារព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយសមស្រប ជាសាធារណៈ ដោយចំណាយថវិការបស់ជនដែលតុលាការរកឃើញថាមានទោសពីបទឧក្រិដ្ឋ ឬតុលាការអាចបញ្ជាឲ្យផ្តល់ថវិកាសម្រាប់សកម្មភាព ឬសេវាកម្មនានាដែលមិនរកប្រាក់ចំណេញ ហើយដែលសកម្មភាពឬសេវានោះគឺដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះទូទៅ។

## សំណួរទី ២៩ ហេតុអ្វីបានជាអង្គការសហប្រជាជាតិចូលរួមពាក់ព័ន្ធក្នុងដំណើរការនេះ ?

នៅខែមិថុនា ឆ្នាំ១៩៩៧ សហនាយករដ្ឋមន្ត្រី គឺសម្តេចក្រុមព្រះ នរោត្តម រណប្ញទ្ធិ និង សម្តេច ហ៊ុន សែន បានសរសេរលិខិតជូនលោក កូហ្វី អាណាន់ ដែលពេលនោះជាអគ្គលេខាធិការអង្គការសហប្រជាជាតិ ដោយស្នើសុំការជួយឧបត្ថម្ភពីអង្គការសហប្រជាជាតិ ក្នុងដំណើរការកាត់ក្តីបទឧក្រិដ្ឋរបស់ខ្មែរក្រហម។ សហនាយករដ្ឋមន្ត្រីបានស្នើសុំការជួយឧបត្ថម្ភខាងលើ ពីព្រោះយល់ឃើញថា វិស័យតុលាការនៅកម្ពុជាខ្វះធនធាននិងជំនាញក្នុងការបំពេញភារកិច្ចដ៏ស្មុគស្មាញជាពិសេសដោយសារបទឧក្រិដ្ឋទាំងនោះមានទំហំធំក្រៃលែង។

Source: United Nations



*ឯកឧត្តម សុខ អាន ដែលកាលនោះជាទេសរដ្ឋមន្ត្រី ជួបជាមួយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ នៅខែមករា ឆ្នាំ២០០៣ ដើម្បីពិភាក្សាអំពីការបង្កើតតុលាការខ្មែរក្រហម*

## សំណួរទី ៣០ ហេតុអ្វីបានជាអតីតមេដឹកនាំខ្មែរក្រហមមិនត្រូវបានយកទៅជំនុំជម្រះក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) នៅទីក្រុងឡាអេ ឬក្នុងតុលាការយុត្តិធម៌អន្តរជាតិ(ICJ) ?

តុលាការឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានបង្កើតឡើងនៅទីក្រុងឡាអេ ប្រទេសហូឡង់ នៅឆ្នាំ២០០២។ កម្ពុជាក៏ជាសមាជិកហត្ថលេខីរបស់តុលាការនេះដែរ។ ក៏ប៉ុន្តែ តុលាការនេះអាចបើកសវនាការនិងដោះស្រាយតែករណីទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្រោយពេលបង្កើតតុលាការនេះតែប៉ុណ្ណោះ។ រីឯតុលាការយុត្តិធម៌អន្តរជាតិធ្វើការជំនុំជម្រះក្តីតែសំណុំរឿងរវាងរដ្ឋនិងរដ្ឋតែប៉ុណ្ណោះ។

## សំណួរទី ៣១ តើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាតុលាការកម្ពុជាឬជាតុលាការអន្តរជាតិ ?

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្ថិតក្នុងប្រព័ន្ធតុលាការកម្ពុជា។ ទោះជាយ៉ាងនេះក្តី តុលាការនេះមានលក្ខណៈពិសេសជាតុលាការ "កូនកាត់" ។ បុគ្គលិកក្នុងតុលាការរួមមាន ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីការពារក្តី ទាំងជាតិនិងអន្តរជាតិ។ ទោះជាយ៉ាងណា មន្ត្រីភាគច្រើនបម្រើការនៅក្នុងតុលាការនេះគឺបុគ្គលិកកម្ពុជា។ ទាំងច្បាប់ជាតិនិងច្បាប់អន្តរជាតិ នឹងត្រូវយកមកប្រើប្រាស់ក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ។

## សំណួរទី ៣២ តើមានតុលាការផ្សេងទៀតនៅក្នុងពិភពលោកដែលមានលក្ខណៈដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ ?

តុលាការកូនកាត់ប្រភេទនេះត្រូវបានបង្កើតឡើងនៅពេលកន្លងទៅថ្មីៗនេះក្នុងប្រទេសមួយចំនួនរួមមាន សៀរ៉ាឡេអូន ទីម័រខាងកើត  កូសូវ៉ូ និង បូស្នៀ ប៉ុន្តែតុលាការនីមួយៗមានរចនាសម្ព័ន្ធដោយឡែកៗពីគ្នា។

## សំណួរទី ៣៣ តើហេតុអ្វីបានជាតុលាការប្រភេទនេះត្រូវបានយកមកប្រើសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ?

គំរូតុលាការកូនកាត់នេះត្រូវបានគេមើលឃើញថាជាមធ្យោបាយមួយដើម្បីផ្តល់ឱកាសឲ្យមានការចូលរួមនិងការពាក់ព័ន្ធយ៉ាងពេញទំហឹងពីសំណាក់ប្រជាជន និងមន្ត្រីកម្ពុជាទូទាំងប្រទេសនៅក្នុងដំណើរការកាត់ក្តីនេះ ហើយទន្ទឹមនឹងនេះ ធានាឲ្យបានតាមបទដ្ឋានអន្តរជាតិ។ មិនដូចសាលាក្តីសម្រាប់ប្រទេសរ៉្វាន់ដា ឬសាលាក្តីសម្រាប់អតីតយូហ្គោស្លាវី ការជំនុំជម្រះក្តីនៅសាលាក្តីនេះមិនធ្វើឡើងនៅឆ្ងាយពីកន្លែងបទឧក្រិដ្ឋកម្មកើតឡើងឡើយ។ សាលាក្តីនេះ ប្រព្រឹត្តទៅនៅប្រទេសកម្ពុជា ហើយដំណើរការកាត់ក្តីត្រូវធ្វើឡើងភាគច្រើនជាភាសាខ្មែរ និងបើកចំហឲ្យមានការចូលរួមពីប្រជាជនកម្ពុជា និងត្រូវបានផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងសារព័ត៌មានក្នុងស្រុក។



រូបថតឧបត្ថម្ភដោយ ហេង ស៊ីនិត

*សិស្សានុសិស្សរាប់ពាន់នាក់នៅវិទ្យាល័យមួយក្នុងរាជធានីភ្នំពេញ ស្តាប់បទឧទ្ទេសនាមអំពីដំណើរការនៃ អ.វ.ត.ក*

## សំណួរទី ៣៤ តើត្រូវចំណាយថវិកាប៉ុន្មានសម្រាប់ដំណើរការកាត់ក្តីនេះ ?

ការចំណាយសម្រាប់ដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាប់ពីឆ្នាំ២០០៦ រហូតដល់ខែធ្នូ ឆ្នាំ២០០៩ មានចំនួន ៧៨,៤ លានដុល្លារអាមេរិក។ ថវិកាសម្រាប់ឆ្នាំ២០១០ មានចំនួន ៤៥,៥ លានដុល្លារ និងសម្រាប់ឆ្នាំ២០១១ មានចំនួន ៤៦,៨ លានដុល្លារ។ តួលេខថវិកានេះប្រហាក់ប្រហែលនឹងតុលាការពិសេសនៅសៀរ៉ាឡេអូន និងទាបជាងច្រើន បើប្រៀបធៀបនឹងការចំណាយរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា (សាលាក្តីនីមួយៗ ចំណាយអស់ប្រមាណ ១៥០ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំៗ)។

## សំណួរទី ៣៥ តើតុលាការនេះទទួលថវិកាមកពីប្រភពណា ?

រដ្ឋាភិបាលជាង ៣៥ ប្រទេស បានចូលរួមជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់វិភាគទានស្ម័គ្រចិត្តសម្រាប់គាំទ្រតុលាការនេះ។ វិភាគទានដែលផ្តល់ឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានដាក់ដោយឡែកពីមូលនិធិម្ចាស់ជំនួយផ្តល់សម្រាប់ការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា។ ប្រទេសជប៉ុនបានផ្តល់ថវិកាជិត ៥០ភាគរយនៃប្រាក់វិភាគទានដែលទទួលបានពីអន្តរជាតិ ដើម្បីគាំទ្រតុលាការនេះ ក្រៅពីនេះ មានប្រទេសម្ចាស់ជំនួយធំៗ ដូចជា ប្រទេសបារាំង ប្រទេសអាល្លឺម៉ង់ ចក្រភពអង់គ្លេស ប្រទេសអូស្ត្រាលី និងសហរដ្ឋអាមេរិក។

ប្រទេសជប៉ុននិងសហគមន៍អឺរ៉ុបគឺជាដៃគូផ្តល់ជំនួយសំខាន់ជាងគេដល់ថវិកាសម្រាប់ភាគីកម្ពុជា។ បន្ថែមលើនេះ គឺមានថវិកាជាង ៥ លានដុល្លារអាមេរិកដែលនៅសល់ពីសម័យអ៊ុនតាក់ (UNTAC) ត្រូវបានសហគមន៍ផ្តល់ជំនួយយល់ព្រមឲ្យកម្ពុជាយកមកប្រើប្រាស់សម្រាប់ចំណាយលើអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមចំណែក ៤,៨ លានដុល្លារសហរដ្ឋអាមេរិកបន្ថែមពីលើការចូលវិភាគទានជាសម្ភារៈ ដូចជាផ្តល់ដល់ការស្ថាបនាបរិវេណនិងចំណាយសម្រាប់មន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។

រហូតមកដល់ពេលនេះ នៅតែមានតម្រូវការជាបន្ទាន់ក្នុងការប្រមូលថវិកាសម្រាប់បន្តដំណើរការងាររបស់សាលាក្តីនេះ។ យើងរំពឹងថានឹងបន្តទទួលបាននូវការគាំទ្រនិងផ្តល់ថវិកាពីប្រទេសផ្តល់ជំនួយ ឬពីអង្គការ ក្រុមហ៊ុន មូលនិធិ ឬបុគ្គលនានា។

## សំណួរទី ៣៦ តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមអំពីរឿងខ្មែរក្រហម និងដំណើរការកាត់ក្តីទាំងនេះដោយវិធីណា?

ផ្នែកកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាកន្លែងដែលត្រូវទាក់ទងមុនគេសម្រាប់ព័ត៌មានអំពីតុលាការ។

សូមទាក់ទងផ្នែកកិច្ចការសាធារណៈតាមរយៈសារអេឡិចត្រូនិកៈ
pas@eccc.gov.kh ទូរស័ព្ទៈ +៨៥៥ (០២៣) ២១៩ ៨១៤ ឬ
ទូរសារៈ +៨៥៥ (០២៣) ២១៩ ៨៤១
គេហទំព័រៈ http://www.eccc.gov.kh/

ប្រព័ន្ធសារព័ត៌មាននិងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ក៏ផ្តល់ព័ត៌មានស្តីពីសាលាក្តីកាត់ទោសខ្មែរក្រហមដែរ។ (សម្រាប់ព័ត៌មានលម្អិត សូមអានទំព័រ *ប្រភពព័ត៌មាន*)



រូបថតៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

*ទាំងសារព័ត៌មានជាតិនិងអន្តរជាតិ តាមដាននិងផ្សព្វផ្សាយជាប្រចាំអំពីដំណើរការនៃ អ.វ.ត.ក*




*អ.វ.ត.ក នៅលើកញ្ចក់ទូរទស្សន៍៖ មន្ត្រីតុលាការនិងផ្នែកពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០១ នៅក្នុងកិច្ចពិភាក្សាតុមូលនៅក្នុងស្ទូឌីយោ ទូរទស្សន៍ជាតិកម្ពុជា មុនពេលប្រកាសសាលក្រមក្នុងសំណុំរឿង ០០១*

រូបថត៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

## សំណួរទី ៣៧ តើអង្គការក្រៅរដ្ឋាភិបាលមានតួនាទីអ្វីខ្លះ ?

អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិជាច្រើនមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម។ ការគាំទ្ររបស់ពួកគេរួមមានការផ្តល់ការពិគ្រោះយោបល់ផ្នែកចិត្តសាស្ត្រដល់សាក្សីនិងជនរងគ្រោះ និងការផ្តល់ព័ត៌មាន ឬការប្រឹក្សាច្បាប់ និងតំណាងកូនក្តី។

## សំណួរទី ៣៨ តើខ្ញុំអាចទទួលសេវាកម្មគាំទ្រសម្រាប់រូបខ្ញុំនៅទីណាបាន ?

ផ្នែកគាំពារជនរងគ្រោះ និងអង្គភាពគាំពារសាក្សី/អ្នកជំនាញ ផ្តល់ជំនួយជាច្រើនដល់សាក្សីនិងអ្នកជំនាញ។ រដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនផ្តល់សេវាកម្មសុខភាពផ្លូវចិត្ត ខណៈដែលអង្គការក្រៅរដ្ឋាភិបាល និងសមាគមមួយចំនួនទៀត ផ្តល់ជំនួយផ្លូវច្បាប់ និងសេវាកម្មផ្សព្វផ្សាយព័ត៌មាន។ (សម្រាប់ព័ត៌មានលម្អិត សូមអានទំព័រ*ប្រភពព័ត៌មាន*)



*ប្រជាជនកម្ពុជានៅទូទាំងប្រទេសស្វែងយល់អំពីដំណើរការរបស់ អ.វ.ត.ក តាមរយៈកម្មវិធីផ្សព្វផ្សាយរបស់តុលាការនេះ។ ប្រជាជនជាង ៣១.៤០០នាក់ បានមកចូលរួមស្តាប់សវនាការក្នុងសំណុំរឿង ០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច ហើយជាង៣ម៉ឺន២ពាន់នាក់ផ្សេងទៀតបានចូលរួមក្នុងកម្មវិធីទស្សនកិច្ចសិក្សារបស់ អ.វ.ត.ក ក្នុងឆ្នាំ២០១០។ សៀវភៅសាលក្រម ឌុច ជិត ៣ម៉ឺនក្បាល ត្រូវបានចែកចាយដោយឥតគិតថ្លៃដល់សាធារណជន ទូទាំងប្រទេស។*



*ដំណើរទស្សនកិច្ចជាប្រវត្តិសាស្ត្រនៅ អ.វ.ត.ក ដោយ ឯកឧត្តម បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០។*
*ក្នុងរូបថតនេះពីឆ្វេងទៅស្តាំ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន ឯកឧត្តម បាន គីមូន លោកស្រី ប៉ាទ្រីសា អូប្រាណ អគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកច្បាប់*
*និងលោក ឃ្នុត រ៉ូសិនហក អនុប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ។*

# ប្រភពព័ត៌មានទាក់ទងនឹង អ.វ.ត.ក

## ប្រព័ន្ធផ្សព្វផ្សាយ

### តាមរយៈការអានឯកសារ

កាសែតក្នុងស្រុកទាំងអស់តែងតែបោះពុម្ពផ្សាយអត្ថបទទាក់ទិននឹងការវិវឌ្ឍនៃ អ.វ.ត.ក ជាប្រចាំ។ តុលាការក៏បានចេញផ្សាយព្រឹត្តិប័ត្រព័ត៌មានប្រចាំខែតាមប្រព័ន្ធអ៊ីនធឺណិតដែលអាចអានបាននៅគេហទំព័រ អ.វ.ត.ក **www.eccc.gov.kh**។ ឯកសារបោះពុម្ពផ្សាយដោយ អ.វ.ត.ក រួមទាំងសៀវភៅសាលក្រមសំណុំរឿង០០១ អាចរកអានបាននៅតាមបណ្ណាល័យជាតិ និងសាលាឃុំ/ស្រុក/ខ័ណ្ឌ/ខេត្ត/ក្រុង ទូទាំងប្រទេស។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតបណ្ណាល័យសាធារណៈនៅទីក្រុងភ្នំពេញ ដែលប្រជាជនអាចមកស្វែងយល់ព័ត៌មានតាមរយៈឯកសារ សៀវភៅ រូបថត ទស្សនាវដ្តី និងវីដេអូ ដែលទាក់ទងនឹងប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅ និងទស្សនាវដ្តី *ស្វែងរកការពិត* សម្រាប់ចែកផ្សាយទូទាំងប្រទេស។

### តាមរយៈអ៊ីនធឺណិត

លោកអ្នកអាចស្វែងរកព័ត៌មានទាន់ហេតុការណ៍ទាក់ទងនឹងរឿងការជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហមតាមរយៈគេហទំព័រ៖ www.eccc.gov.kh។ អត្ថបទ រូបភាព និងវីដេអូទាន់ហេតុការណ៍ ក៏អាចរកមើលបានក្នុងបណ្តាញទំនាក់ទំនងសង្គមដូចជា

Facebook: **www.facebook.com/krtribunal**

YouTube: **www.youtube.com/krtribunal**

Flickr: **www.flickr.com/krtribunal**

Twitter: **twitter.com/krtribunal**

សូមអាននៅគេហទំព័រ **www.unakrt-online.org** សម្រាប់ព័ត៌មានទាក់ទងនឹងជំនួយអង្គការសហប្រជាជាតិដល់ អ.វ.ត.ក។

មានការផ្សាយ Webcast នៃដំណើរការនីតិវិធីតុលាការនៅលើគេហទំព័រ **www.cambodiatribunal.org**។

*មានគេហទំព័រផ្សេងទៀតដែលមានទំនាក់ទំនងជាមួយសាលាក្តីខ្មែរក្រហម ដូចជា ៖*

មជ្ឈមណ្ឌលឯកសារកម្ពុជា **www.dccam.org**

កម្មវិធីស្រាវជ្រាវការប្រល័យពូជសាសន៍នៅកម្ពុជារបស់សាកលវិទ្យាល័យយែល **www.yale.edu.org**

ក្រុមតាមដានអំពើប្រល័យពូជសាសន៍ **www.genocidewatch.org**

វេទិកាសាធារណៈ: **www.krtrial.info**

### តាមរយៈវិទ្យុ

**វិទ្យុជាតិកម្ពុជា** (FM ៩៦ FM ១០៥.៧៥ និង AM ៩១៨) និងទាំងស្ថានីយ៍វិទ្យុឯកជន និងអង្គការក្រៅរដ្ឋាភិបាលទាំងអស់ ធ្វើសេចក្តីរាយការណ៍ព័ត៌មានជាទៀងទាត់អំពីដំណើរការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយមានផ្សាយកម្មវិធីពិសេសដូចខាងក្រោម៖

### មណ្ឌលព័ត៌មានស្ត្រីកម្ពុជា

ផ្សាយកម្មវិធីជាទៀងទាត់រៀងរាល់សប្តាហ៍ (ផ្សាយតាមវិទ្យុ FM ១០២ ក្រុងភ្នំពេញ) ក្នុងកម្មវិធី "ការពិត" ដែលបង្ហាញព័ត៌មានទាក់ទិននឹងខ្មែរក្រហម និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

- ថ្ងៃច័ន្ទ ម៉ោង ៤:00 – ៥:00 ល្ងាច (កម្មវិធីសន្ទនាតាមទូរស័ព្ទ/ជជែកពិភាក្សា)
- ថ្ងៃអង្គារ ម៉ោង ៦:៣០ – ៧:00 យប់ (ចាក់ផ្សាយឡើងវិញ)
- ថ្ងៃព្រហស្បតិ៍ ម៉ោង ១:៣០ – ២:00 រសៀល (ចាក់ផ្សាយឡើងវិញ)
- ថ្ងៃសុក្រ ម៉ោង១០:៥០ – ១១:៥០ ថ្ងៃត្រង់ (កម្មវិធីទទួលទូរស័ព្ទ/ចាក់ផ្សាយឡើងវិញ កម្មវិធីជជែកពិភាក្សា)
- ថ្ងៃសៅរ៍ ម៉ោង ៦:៣០ – ៧:00 ព្រឹក (ចាក់ផ្សាយឡើងវិញ)
- ថ្ងៃអាទិត្យ ម៉ោង ១៣:00 – ១៣:៣០ រសៀល (ចាក់ផ្សាយឡើងវិញ)

### អង្គការក្រុមអ្នកច្បាប់គាំទ្រសិទ្ធិកម្ពុជា (CDP)

ផលិតកម្មវិធីប្រចាំខែសន្ទនាតាមទូរស័ព្ទ " ស្ត្រី និងរបបខ្មែរក្រហម" ដែលចាក់ផ្សាយពី៖

- វិទ្យុ FM ១០២ ថ្ងៃអង្គារសប្តាហ៍ទី ៤ រៀងរាល់ខែ ពីម៉ោង ៣:00 – ៤:00 រសៀល
- វិទ្យុ FM ១០២ ថ្ងៃអង្គារសប្តាហ៍ទី ១ រៀងរាល់ខែ ពីម៉ោង ៣:00 – ៣:៣០ រសៀល (ចាក់ផ្សាយឡើងវិញ)

### មជ្ឈមណ្ឌលឯកសារកម្ពុជា

ផ្សាយតាមវិទ្យុដោយអានអត្ថបទដកស្រង់ចេញពី "ទស្សនាវដ្ដីស្វែងរកការពិត" និងសៀវភៅផ្សេងៗទៀត ដែលបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ៖

- វិទ្យុ FM ៩៣.២៥ ខេត្តកំពត ផ្សាយជាប្រចាំថ្ងៃ ម៉ោង ៧:00 – ៧:៣០ ព្រឹក និងម៉ោង ១៩:00 – ១៩:៣០ យប់។
- គេរំពឹងថា កម្មវិធីនេះនឹងពង្រីកការផ្សព្វផ្សាយទូទាំងប្រទេសក្នុងខែមករា ឆ្នាំ ២០១១

### កម្មវិធីវិទ្យុយុវជនដើម្បីសន្តិភាព៖

- វិទ្យុ AM ៩.១៨ នៅថ្ងៃសៅរ៍ ម៉ោង ១៤:00 – ១៥:00 រសៀល (កម្មវិធីសន្ទនាតាមទូរស័ព្ទ)
- វិទ្យុ FM ១០៦.៥ នៅថ្ងៃអាទិត្យ ម៉ោង ១០:00 – ១១:00 ព្រឹក (ចាក់ផ្សាយឡើងវិញ)

### សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក/ADHOC)

ផលិតនិងផ្សាយតាមវិទ្យុនូវកម្មវិធីសិទ្ធិមនុស្ស រៀងរាល់ថ្ងៃពុធពីម៉ោង ៧.៣០ – ៨.៣០ ព្រឹក អំពីព័ត៌មានទាក់ទងនឹងសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម។ កម្មវិធីនេះត្រូវបានផ្សាយឡើងវិញនៅខេត្តមួយចំនួន៖

- វិទ្យុ FM ៩០ និង វិទ្យុ FM ១០៥ ទីក្រុងភ្នំពេញ ថ្ងៃពុធ ម៉ោង៧:៣០ – ៨:៣០ ព្រឹក (កម្មវិធីសន្ទនាតាមទូរស័ព្ទ)
- វិទ្យុ FM ៩០.២៥ ខេត្តបាត់ដំបង ថ្ងៃពុធ ម៉ោង៧:៣០ – ៨:៣០ ព្រឹក (កម្មវិធីសន្ទនាតាមទូរស័ព្ទ)
- វិទ្យុ FM ៩៣.៧៥ ខេត្តកំពត ថ្ងៃច័ន្ទក្នុងសប្តាហ៍ទី១ ម៉ោង១២:00 – ១៣:00 រសៀល (ចាក់ផ្សាយឡើងវិញ)
- វិទ្យុ FM ៩៨.៥០ ខេត្តពោធិ៍សាត់ ថ្ងៃច័ន្ទក្នុងសប្តាហ៍ទី ១ ម៉ោង៦:00 – ៧:00 ព្រឹក (ចាក់ផ្សាយឡើងវិញ)
- វិទ្យុ FM ៩៨.៣ ខេត្តកំពង់ធំ ថ្ងៃពុធក្នុងសប្តាហ៍ទី ១ ម៉ោង៧:៣០ – ៨:៣០ ព្រឹក (ចាក់ផ្សាយឡើងវិញ)

- វិទ្យុ FM ១០៣.៧៥ ខេត្តស្វាយរៀង ថ្ងៃអាទិត្យ ក្នុងសប្តាហ៍ទី ២ ម៉ោង១៣:០០ – ១៤:០០ រសៀល (ចាក់ផ្សាយឡើងវិញ)
- វិទ្យុ FM ១០៥.៥០ ខេត្តសៀមរាប ថ្ងៃអាទិត្យ ក្នុងសប្តាហ៍ទី ២ ម៉ោង៨:០០ – ៩:០០ ព្រឹក (ចាក់ផ្សាយឡើងវិញ)

## កម្មវិធីវិទ្យុរបស់គណៈកម្មាធិការប្រព្រឹត្តកម្មការពារសិទ្ធិមនុស្សនៅកម្ពុជា (CHRAC)

មានឈ្មោះ " កម្មវិធីឃ្លាំមើលដំណើរការសាលាក្តីខ្មែរក្រហម " ដែលផ្សាយតាមវិទ្យុ FM ១០២ រៀងរាល់ថ្ងៃពុធ ពីម៉ោង ១៧:៣០ – ១៨:៣០ ល្ងាច។

## កម្មវិធីសន្ទនាតាមវិទ្យុរបស់អង្គការចិត្តសង្គម-អន្តរវប្បធម៌ (TPO)

ដែលមានឈ្មោះថា " អតីតក្នុងបច្ចុប្បន្ន " ចាក់ផ្សាយតាមវិទ្យុ FM ១០២ នៅសប្តាហ៍ទី ២ និងទី ៤ រៀងរាល់ខែ៖

- ថ្ងៃព្រហស្បតិ៍ ម៉ោង ៦:៣០ – ៧.០០ ព្រឹក (ចាក់ផ្សាយឡើងវិញ)
- ថ្ងៃសុក្រ ម៉ោង ១៥:០០ – ១៦.០០ រសៀល (ផ្សាយផ្ទាល់)
- ថ្ងៃសៅរ៍ ម៉ោង ១៥:៣០ – ១៦.០០ រសៀល (ចាក់ផ្សាយឡើងវិញ)

## វិទ្យុអាស៊ីសេរី (RFA)

ផ្សាយជាភាសាខ្មែរតាមរយៈ

- វិទ្យុ AM ១៣.៨៦៥ KHz និង AM ១៥.៧៨៥ KHz ម៉ោង ១៩:៣០-២០:៣០ យប់
- វិទ្យុ AM ៧.៥៨០ KHz និង AM ១៣.៧៤០ KHz ម៉ោង ៥:៣០-៦:៣០ ព្រឹក
- វិទ្យុ FM ១០៥ ម៉ោង ៦:០០ – ៧:០០ ព្រឹក និងម៉ោង ២០:៣០ – ២១:៣០ យប់
- វិទ្យុ FM ១០២ ម៉ោង ៧:០០ – ៨:០០ ព្រឹក និងម៉ោង ២២:៣០ – ២៣:៣០ យប់
- វិទ្យុ FM ៩៣.៥ ម៉ោង ៦:០០ – ៧:០០ ព្រឹក និងម៉ោង ២០:០០ – ២១:០០ យប់

## វិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA)

ផ្សាយជាភាសាខ្មែរតាមរយៈ

- វិទ្យុ AM ១៥៧៥, AM៦០៦០, AM ៧១៣០ និង AM ១៥៣៤០ ម៉ោង ៥:០០ – ៥:៣០ ព្រឹក
- វិទ្យុ AM ១៥៧៥, AM ៥៩៥៥ និង AM ៧១៥៥ ម៉ោង ២០:៣០-២១:៣០ យប់
- វិទ្យុ FM ១០៥ ម៉ោង ៧:០០ – ៧:៣០ ព្រឹក និងម៉ោង ២១:៣០ – ២២:៣០ យប់។
- វិទ្យុ FM ៩៣.៥ ម៉ោង ៥:៣០ – ៦:០០ ព្រឹក
- វិទ្យុ FM ១០២ រៀងរាល់ថ្ងៃ ម៉ោង ៦:០០ – ៦:៣០ ព្រឹក និងម៉ោង ២០:៣០ – ២១:៣០ យប់

## វិទ្យុអូស្ត្រាលី ABC (Radio Australia)

ផ្សាយជាភាសាខ្មែរ ម៉ោង១២:០០ – ១៣:០០ រសៀល តាមរយៈ

- វិទ្យុ FM ១០២ ក្រុងភ្នំពេញ
- វិទ្យុ FM ៩៦.៥ ខេត្តបន្ទាយមានជ័យ
- វិទ្យុ FM ១០១.៥ ខេត្តសៀមរាប
- វិទ្យុ FM ៩២.៧៥ ខេត្តបាត់ដំបង
- វិទ្យុ FM៩៨.៥ ខេត្តក្រចេះ

ហើយផ្សាយជាភាសាអង់គ្លេស ២៤ ម៉ោងក្នុងមួយថ្ងៃ តាមរយៈវិទ្យុ FM ១០១.៥ នៅភ្នំពេញ និងខេត្តសៀមរាប។

## វិទ្យុបារាំងអន្តរជាតិ (RFI)

ផ្សាយជាភាសាខ្មែរ ម៉ោង ១៩:០០-២០:០០ យប់ តាមរយៈវិទ្យុ៖

- វិទ្យុ FM ៩២ ក្រុងភ្នំពេញ
- វិទ្យុ FM ៩២ ខេត្តសៀមរាប
- វិទ្យុ FM ៩៤.៥ ខេត្តបាត់ដំបង
- វិទ្យុ FM ៩៤.៥ ខេត្តកំពង់ចាម
- វិទ្យុ FM ៩៤.៥ ក្រុងព្រះសីហនុ

វិទ្យុ FM ១០២ ក្រុងភ្នំពេញ ម៉ោង ២១:៣០ – ២២:៣០ យប់ និងផ្សាយជាភាសាបារាំង ២៤ ម៉ោងក្នុងមួយថ្ងៃ តាមរយៈវិទ្យុ FM ៩២ នៅភ្នំពេញ។

## តាមរយៈទូរទស្សន៍

គ្រប់ស្ថានីយ៍ទូរទស្សន៍កម្ពុជាទាំងអស់ផ្សាយព័ត៌មានជាទៀងទាត់អំពីដំណើរវិវឌ្ឍន៍របស់ អ.វ.ត.ក ក្នុងនាទីព័ត៌មាន ឬកម្មវិធីសាធារណៈរបស់ខ្លួន។ កម្មវិធីពិសេសត្រូវបានផ្សាយពីស្ថានីយ៍ទូរទស្សន៍ចំនួន ៣ ខាងក្រោមនេះ ៖

### ទូរទស្សន៍ស៊ីធីអិន (CTN)

មានរថយន្តពិសេសប្រចាំនៅសាលាក្តីខ្មែរក្រហម ដើម្បីផ្សាយផ្ទាល់នូវដំណើរការកាត់ក្តីទាំងស្រុង និងផ្សាយព័ត៌មានជាញឹកញាប់អំពី អ.វ.ត.ក ក្នុងកម្មវិធីពេលព្រឹកនិងកម្មវិធីព័ត៌មាន។

### ទូរទស្សន៍ជាតិកម្ពុជា (TVK)

ផ្សាយព័ត៌មានជាញឹកញាប់អំពី អ.វ.ត.ក ក្នុងកម្មវិធីព័ត៌មាន។

### ទូរទស្សន៍អប្សរា (APSARA)

ផ្សាយព័ត៌មានជាញឹកញាប់អំពី អ.វ.ត.ក ក្នុងកម្មវិធីព័ត៌មាន។

### ទូរទស្សន៍អន្តរជាតិ ជាពិសេសទូរទស្សន៍ BBC

ទូរទស្សន៍ **Al Jazeera** ទូរទស្សន៍ **CNN** ទូរទស្សន៍ **NHK** ទូរទស្សន៍ **Channel News Asia** ក៏ផ្សព្វផ្សាយពីព័ត៌មានទាន់ហេតុការណ៍របស់ អ.វ.ត.ក ដែរ។

## អង្គការសម្រាប់ទំនាក់ទំនង និងផ្តល់ព័ត៌មានជាសាធារណៈ

### មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា

**Bophana Audiovisual Resource Centre**

ផ្ទះលេខ ៦៤ ផ្លូវលេខ ២០០ ឧកញ៉ាម៉ែន
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ១២២១១ កម្ពុជា
ទូរស័ព្ទ : ០២៣ ៩៩២ ១៧៤
សារអេឡិចត្រូនិក: archives@bophana.org.kh
archives@bophana.org
គេហទំព័រ ៖ www.bophana.org

### គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា

**Cambodia Human Rights Action Committee (CHRAC)**

ផ្ទះលេខ ៩ ផ្លូវលេខ ៣៣០
សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន ក្រុងភ្នំពេញ
ប្រអប់សំបុត្រលេខ: ៤៩៩ ភ្នំពេញ
ទូរស័ព្ទ និងទូរសារ: ០២៣ ៣៥១ ៤១៥
សារអេឡិចត្រូនិក: chrac@forum.org.kh

### សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក)

**Cambodia Human Rights and Development Association (ADHOC)**

ផ្ទះលេខ ៣ ផ្លូវលេខ ១៥៨ សង្កាត់បឹងរាំង
ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទនិងទូរសារ: ០២៣ ៩៩០ ៥៤៤
សារអេឡិចត្រូនិក: adhoc@forum.org.kh

### គម្រោងយុត្តិធម៌សង្គមសេរី

**Cambodia Justice Initiative (CJI/OSJI)**

មណ្ឌលភ្នំពេញ ជាន់ទី ២ បន្ទប់លេខ ២២២
ទូរស័ព្ទ និងទូរសារ: ០២៣ ២២១ ៧៩៣
សារអេឡិចត្រូនិក: cji@online.com.kh

មជ្ឈមណ្ឌលឯកសារកម្ពុជា
**Documentation Center of Cambodia (DC-Cam)**
ផ្ទះលេខ ៦៦គ មហាវិថីព្រះសីហនុ ក្រុងភ្នំពេញ
ទូរស័ព្ទ: ០២៣ ២១១ ៨៧៥
ទូរសារ: ០២៣ ២១០ ៣៥៨
សារអេឡិចត្រូនិក: dccam@online.com.kh

មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការផ្សះផ្សានៅកម្ពុជា
**International Centre for Conciliation Cambodia (ICFC)**
ផ្ទះលេខ ៩៦ មហាវិថីសុធារស
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ៦៩៥ ៦៥ ១២
សារអេឡិចត្រូនិច: Cambodia@centerforconciliation.org
គេហទំព័រ: www.centerforconciliation.org

វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ
**Khmer Institute for Democracy (KID)**
ផ្ទះលេខ ៥ ផ្លូវលេខ ៥៧ ក្រុងភ្នំពេញ
ទូរស័ព្ទ: ០២៣ ២១៤ ៩២៨
ទូរសារ: ០២៣ ២១៦ ២០៦
សារអេឡិចត្រូនិក: director.kid@online.com.kh

មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា
**Women's Media Center of Cambodia (WMC)**
ផ្ទះលេខ ៣០ ផ្លូវលេខ ៤៨៨ /៤៨៤ ភ្នំពេញ
ទូរស័ព្ទនិងទូរសារ: ០២៣ ២២៣ ៥៩
សារអេឡិចត្រូនិក: wmc@online.com.kh

អង្គការយុវសន្តិភាព
**Youth for Peace (YFP)**
ផ្ទះលេខ ៤-៦ G ផ្លូវលេខ ៥១៣
សង្កាត់បឹងកក់១ ខណ្ឌទួលគោក ភ្នំពេញ
ទូរស័ព្ទនិងទូរសារ: ០២៣ ៨៨១ ៣៤៦
សារអេឡិចត្រូនិក: admin@yfpcambodia.org
គេហទំព័រ: www.yfpcambodia.org

## អង្គការគាំទ្រ និង ផ្តល់ជំនួយផ្នែកច្បាប់

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
**The Bar Association of the Kingdom of Cambodia (BACK)**
ផ្ទះលេខ ១០-១១ ផ្លូវកាកបាទក្រហមខ្មែរ (ផ្លូវ ១៨០)
សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ
ប្រអប់សំបុត្រ ១៥៨៧
ទូរស័ព្ទ: ០២៣ ២២០ ២៣៧
ទូរសារ: ០២៣ ២១៣ ៦៥៨

ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្ស
**Cambodia Defenders Project (CDP)**
ផ្ទះលេខ ១២ ផ្លូវល្វាឯម (ផ្លូវលេខ ២៨២) ភ្នំពេញ
ទូរស័ព្ទ: ០២៣ ៧២០ ០៣២
ទូរសារ: ០២៣ ៧២០ ០៣១
សារអេឡិចត្រូនិក: cbdp@cdpcambodia.org

សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក)
**Cambodia Human Rights and Development Association (ADHOC)**
ផ្ទះលេខ ៣ ផ្លូវលេខ ១៥៨ សង្កាត់បឹងរាំង
ខ័ណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទនិងទូរសារ: ០២៣ ៩៩០ ៥៤៤
សារអេឡិចត្រូនិក: adhoc@forum.org.kh

ជំនួយផ្នែកច្បាប់នៃកម្ពុជា
**Legal Aid of Cambodia (LAC)**
ផ្ទះលេខ ១៨ ផ្លូវលេខ ៦០៤
សង្កាត់បឹងកក់ ២ ខ័ណ្ឌទួលគោក ភ្នំពេញ

ប្រអប់សំបុត្រលេខ ១១៦៧
ទូរស័ព្ទ: ០២៣ ៨៨៤ ២៦២
សារអេឡិចត្រូនិក: lac@online.com.kh

# អង្គការពិគ្រោះយោបល់ និង ផ្តល់សេវាសុខភាពផ្លូវចិត្ត

### អង្គការចិត្តសង្គម-អន្តរវប្បធម៌
**Transcultural Psychosological Organization (TPO)**

ផ្ទះលេខ២ & ៤ កាច់ជ្រុងផ្លូវហាណូយ & ផ្លូវឧកញ្ញាវាំង ភ្នំពេញថ្មី ភ្នំពេញ
ប្រអប់សំបុត្រលេខ: ១១២៤
សារអេឡិចត្រូនិក: admin@tpocambodia.org
លេខទូរស័ព្ទ: ០២៣ ៦៣ ៦៦ ៩៩១/២/៣

### អង្គការចិត្តសង្គម-អន្តរវប្បធម៌ ខេត្តបាត់ដំបង
**(TPO Battambang)**

ភូមិរំចេក៤ ឃុំរតនៈ ក្រុងបាត់ដំបង
លេខទូរស័ព្ទ: ០៥៣ ៦៣៣ ៣៦១១
សារអេឡិចត្រូនិក: tpobtb@camintel.com

### អង្គការចិត្តសង្គម-អន្តរវប្បធម៌ ខេត្តសៀមរាប
**(TPO Siem Reap)**

ផ្ទះលេខ ១៣៨ ភូមិមណ្ឌល ៣ ឃុំស្លក្រាម
លេខទូរស័ព្ទ: ០៥៣ ៦៣៣ ៣៦១១
សារអេឡិចត្រូនិក: tposr@camintel.com

### អង្គការចិត្តសង្គម-អន្តរវប្បធម៌ ខេត្តបន្ទាយមានជ័យ
**(TPO Banteay Meanchay)**

ផ្ទះលេខ ១៨ ផ្លូវលេខ ៤ ក្រុម ២៨ ភូមិសូភី ឃុំកំពង់ស្វាយ ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ
លេខទូរស័ព្ទ: ០៥៤ ៦៥២០ ៦៦៦
សារអេឡិចត្រូនិក: tpobmc@camintel.com

### អង្គការចិត្តសង្គម-អន្តរវប្បធម៌ ខេត្តកំពង់ធំ
**(TPO Kampong Thom)**

ផ្ទះលេខ ៣៦ ភូមិទី ៧ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ
លេខទូរស័ព្ទ: ០៦២ ៩៦១ ៣៧៥
សារអេឡិចត្រូនិក: tpoktp@comintel.com

### សេវាសង្គមកិច្ចកម្ពុជា (សសក) ក្រុងភ្នំពេញ ស្ថិតក្នុងវិទ្យាស្ថានជាតិសុខភាពសាធារណៈ

ផ្ទះលេខ ២ ផ្លូវ ២៨៩ ( ផ្លូវគីមអ៊ីលសុង ) ភ្នំពេញ
ប្រអប់សំបុត្រលេខ: ១៤៧៧
លេខទូរស័ព្ទ: ០២៣ ៨៨១ ៤៣២
០២៣ ៨៨១ ៥៣២
ទូរស័ព្ទដៃ: ០១២ ៨១១ ៨២៥
លេខទូរសារ: ០២៣ ៨៨១ ៤៣០
សារអេឡិចត្រូនិក: ssc@online.com.kh

### សេវាសង្គមកិច្ចកម្ពុជា ខេត្តកំពង់ស្ពឺ

ផ្លូវជាតិលេខ ៤ ភូមិឌី ឃុំច្បារមន ស្រុកច្បារមន (ចម្ងាយ ៣ គីឡូម៉ែត្រ ខាងលិចផ្សារកំពង់ស្ពឺ)
លោកស្រី ហេង ស្រី ទូរស័ព្ទ: ០១២ ៨០៣ ៥៣៣

### ចេស្វីតសឺវីសកម្ពុជា
**Jesuit Service Cambodia (JSC)**

ផ្ទះលេខ ៩៦ ផ្លូវលេខ ៥៩២ ខ័ណ្ឌទួលគោក ភ្នំពេញ
លេខទូរស័ព្ទ/ លេខទូរសារ:
០២៣ ៨៨០ ១៣៩/០២៣ ៨៨០ ១៤០
សារអេឡិចត្រូនិក: jrscam@forum.org.kh

## សេវាសុខភាពផ្លូវចិត្តរបស់រាជរដ្ឋាភិបាល

**បន្ទាយមានជ័យ : មន្ទីរពេទ្យមង្គលបូរី**
**ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត**
ភូមិកោះកែវ ឃុំឫស្សីក្រោក
វេជ្ជ. វ៉ាន់ លុច: ០១២ ៦០០ ៣២១
លោក ហូ សេរីវិទូ (ប្រធានមន្ទីរពេទ្យ)

**បាត់ដំបង : មន្ទីរពេទ្យបង្អែកបាត់ដំបង**
**ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត**
ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង
វេជ្ជ. អ៊ុំ ញិល: ០១២ ៨៨៩ ៨៩៧

**កំពង់ចាម : មន្ទីរពេទ្យបង្អែកកំពង់ចាម**
**ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត**
ភូមិ ទី៧ ឃុំកំពង់ចាម ស្រុកកំពង់ចាម
លោក ស សារ៉ុជ: ០១២ ៨៩២ ០៩២

**កំពង់ស្ពឺ : មន្ទីរពេទ្យបង្អែកឧដុង្គ**
**ផ្នែកសុខភាពផ្លូវចិត្ត**
ភូមិពន្លៃ ឃុំវាំងចាស់ ស្រុកឧដុង្គ
លោក គឹម សុភាព: ០១២ ៩១០ ០៦២

**កំពង់ធំ : មន្ទីរពេទ្យបង្អែកកំពង់ធំ**
**ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត**
ឃុំកំពង់ធំ ស្រុកស្ទឹងសែន
វេជ្ជ. អ៊ិត ប៊ុនគី : ០១១ ៨៦៤ ៨៨៧

**កំពត : មន្ទីរពេទ្យបង្អែក**
**ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត**
លោកស្រី ចាប សុជាតា : ០១២ ៧០០ ១៦៧

**កណ្តាល : មន្ទីរពេទ្យជ័យជំនះ**
**មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ**
ផ្ទះលេខ ៤៧ ផ្លូវ ១៩៨ ក្រុងតាខ្មៅ
លេខទូរស័ព្ទ: ០២៣ ៣០០ ៥៣៤/៩៨៣ ៣៤៨
វេជ្ជ.ភូមី កុមារ Bhoomi Kumar : ០១២ ៤៨២ ៨៥៤

**ភ្នំពេញ : មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត**
**ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត**
លោកសាស្ត្រាចារ្យ ការ ស៊ិនបូណាត :
០១២ ៨៦៥ ៤៤០
វេជ្ជ. អាង សូឌី : ០១២ ៦២២ ៤៨៧

**ព្រះវិហារ : មន្ទីរពេទ្យបង្អែកព្រះវិហារ**
**ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត**
ភូមិឡូតជួ ឃុំកំពង់ត្រណាក់ ស្រុកត្បែងមានជ័យ
វេជ្ជ. ជូ ប៉ូលីណា : ០១២ ៩៦៨ ៣២៨

**ពោធិ៍សាត់ : មន្ទីរពេទ្យបង្អែកខេត្តពោធិ៍សាត់**
**សេវាសុខភាពផ្លូវចិត្ត**
ឃុំផ្កាកព្រៃ ស្រុកសំពៅមាស
វេជ្ជ. តេង ហុកលី : ០១២ ៩៨៩ ៣០៦

**សៀមរាប : មន្ទីរពេទ្យបង្អែក**
**ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត**
ភូមិមណ្ឌល ១ ឃុំស្វាយដង្គំ ស្រុកសៀមរាប
លោក មុំ សុវណ្ណារ៉ា : ០១២ ៧០០ ៨៩៩

**ស្វាយរៀង : មន្ទីរពេទ្យបង្អែក**
**សេវាសុខភាពផ្លូវចិត្ត**
ភូមិស្រះរាង ឃុំស្វាយរៀង ស្រុកស្វាយរៀង
វេជ្ជ. សូ បូរាណ : ០១១ ៦៣៨៣០៧

## សមាគមជនរងគ្រោះ

**សមាគមជនរងគ្រោះដោយរបបខ្មែរក្រហម**
**ក្នុងប្រទេសកម្ពុជា**
សារអេឡិចត្រូនិក: president@akrvc.org

**សមាគមក្សេមក្សាន្ត**
លេខទូរសព្ទ: ០១២ ៧១២ ១៤៨
សារអេឡិចត្រូនិក: info@ksemksan.org




KINGDOM OF CAMBODIA
ROYAUME DU CAMBODGE
E.C.C.C * C.E.T.C






E.C.C.C * C.E.T.C



## ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម

ការបោះពុម្ពលើកទី ១ នៅខែសីហា ឆ្នាំ២០០៤ ដោយក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការបង្កើតសាលាក្តីខ្មែរក្រហម ការិយាល័យទីស្តីការគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

កូនសៀវភៅនេះត្រូវបានកែសម្រួលនិងបន្ថែមព័ត៌មានមួយចំនួនក្នុងការបោះពុម្ពលើកទី ៤ ដោយផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក

ការបោះពុម្ពផ្សាយឡើងវិញទាំងស្រុងឬដោយផ្នែកនៃកូនសៀវភៅនេះ ត្រូវបានអនុញ្ញាតនិងលើកទឹកចិត្ត ប៉ុន្តែត្រូវមានការបញ្ជាក់ពីប្រភព

*ដំណើរឆ្ពោះទៅមុខប្រកបដោយភាពយុត្តិធម៌*

ផ្នែកកិច្ចការសាធារណៈ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ
ទូរស័ព្ទ : +៨៥៥ (0) ២៣ ២១៩ ៨១៤ ទូរសារ : +៨៥៥ (0) ២៣ ២១៩ ៨៤១
សារអេឡិចត្រូនិច : pas@eccc.gov.kh
គេហទំព័រ : www.eccc.gov.kh

អ.វ.ត.ក ក្នុងបណ្តាញទំនាក់ទំនងសង្គម : www.facebook.com/krtribunal
www.flickr.com/krtribunal
www.youtube.com/krtribunal
www.twitter.com/krtribunal

Design by nova: info@novacambodia.com